បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

តម្លៃ ២៧៥០ រៀល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៧ លេខ ៣១ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៩

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្តាហ៍

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៧-៨-១៩៩៩ | -ព្រះរាជក្រឹត្យ ជស/រកត/០៨៩៩/៥៩ តែងតាំងឯកឧត្តម ស ណូត ជាទីប្រឹក្សាផ្ទាល់របស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា | ១៥០៩ |
| ៩-៨-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៨៩៩/១៥២ តែងតាំងឯកឧត្តម ម៉ិច សុខេម ចេញប្បន្ននាយកខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ១៥១០ |
| ១៦-៨-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៨៩៩/១៥៨ តែងតាំងឯកឧត្តម ញ៉ែម ថាវី ជាទីប្រឹក្សាឯកឧត្តម ខួន ញឹល | ១៥១០ |
| ១៦-៨-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៨៩៩/១៥៩ តែងតាំងឯកឧត្តម ញ៉ែម រ៉ុម ជាទីប្រឹក្សាឯកឧត្តម ខួន ញឹល | ១៥១១ |
| ១៦-៨-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៨៩៩/១៦០ តែងតាំងឯកឧត្តម ឡុង ហ៊ីម ជាទីប្រឹក្សាឯកឧត្តម ងួន ញិល | ១៥១២ |
| ១៦-៨-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៨៩៩/១៦១ តែងតាំងឯកឧត្តម អ៊ុង ឿនរិទ្ធ ជាទីប្រឹក្សាឯកឧត្តម ងួន ញិល | ១៥១៣ |


## II- ក្រុមប្រឹក្សាធម្មនុញ្ញ

### សេចក្តីសំរេច


| | | |
|---|---|---|
| ២៣-៩-១៩៩៩ | -សេចក្តីសំរេចលេខ ១២ កបធ.សសរ.ច | ១៥១៣ |


## III- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ១៦-៨-១៩៩៩ | -អនុក្រឹត្យលេខ ៧៤ អនក្រ.បក ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ជាគ្រឹះស្ថានសាធារណរដ្ឋបាល | ១៥១៥ |
| ២០-៨-១៩៩៩ | -អនុក្រឹត្យលេខ ៧៥ អនក្រ.បក ស្តីពីបែបបទសំរាប់អនុវត្តចំពោះ ការអនុញ្ញាតអោយជនបរទេសមិនមែនអន្តោប្រវេសន្ត ចូល ចេញ និងស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា | ១៥២៩ |

| | | |
|---|---|---|
| ២០-៨-១៩៩៩ | -អនុក្រឹត្យលេខ ៧៦ អនក្រ.បក ស្ដីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិតកម្មករប្រចាំឆ្នាំ ២០០០ | ១៥៣៨ |
| ២០-៨-១៩៩៩ | -អនុក្រឹត្យលេខ ៧៧ អនក្រ.បក ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ១៥៣៩ |
| ២៣-៨-១៩៩៩ | -អនុក្រឹត្យលេខ ៧៨ អនក្រ.បក ស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា | ១៥៥៦ |
| ១៦-៨-១៩៩៩ | -អនុក្រឹត្យលេខ ៥៦៤ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋអមចំការកៅស៊ូស្នួល | ១៥៦១ |
| ១៦-៨-១៩៩៩ | -អនុក្រឹត្យលេខ ៥៦៥ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋអមចំការកៅស៊ូជប់ | ១៥៦១ |
| ១៦-៨-១៩៩៩ | -អនុក្រឹត្យលេខ ៥៦៦ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋអមចំការកៅស៊ូមេមត់ | ១៥៦២ |
| ១៦-៨-១៩៩៩ | -អនុក្រឹត្យលេខ ៥៦៧ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋអមចំការកៅស៊ូពាមជាំង | ១៥៦៣ |
| ១៦-៨-១៩៩៩ | -អនុក្រឹត្យលេខ ៥៦៨ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋអមចំការកៅស៊ូក្រែក | ១៥៦៤ |
| ១៦-៨-១៩៩៩ | -អនុក្រឹត្យលេខ ៥៦៩ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋអមចំការកៅស៊ូ ចំការអណ្ដូង | ១៥៦៥ |
| ១៦-៨-១៩៩៩ | -អនុក្រឹត្យលេខ ៥៧០ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋអមចំការកៅស៊ូបឹងកេត | ១៥៦៦ |
| ១៦-៨-១៩៩៩ | -អនុក្រឹត្យលេខ ៥៧១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ១៥៦៧ |
| ១៦-៨-១៩៩៩ | -អនុក្រឹត្យលេខ ៥៧២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ១៥៦៨ |
| ១៦-៨-១៩៩៩ | -អនុក្រឹត្យលេខ ៥៧៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ១៥៦៩ |
| ១៦-៨-១៩៩៩ | -អនុក្រឹត្យលេខ ៥៧៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ១៥៦៩ |
| ១៦-៨-១៩៩៩ | -អនុក្រឹត្យលេខ ៥៧៥ អនក្រ.តត ស្ដីពីការតែងតាំងអភិបាល ស្រុក ខណ្ឌ តាមបណ្ដាខេត្ត-ក្រុង | ១៥៧០ |
| ១៦-៨-១៩៩៩ | -អនុក្រឹត្យលេខ ៥៧៦ អនក្រ.តត ស្ដីពីការតែងតាំងអភិបាលរង តាមបណ្ដាខេត្ត-ក្រុង | ១៥៧១ |
| ១៦-៨-១៩៩៩ | -អនុក្រឹត្យលេខ ៥៧៧ អនក្រ.តត ស្ដីពីការផ្លាស់ប្ដូរមន្ត្រីរាជការ | ១៥៧២ |

# គី


១៦-៨-១៩៩៩ -អនុក្រឹត្យលេខ ៨៧៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥៧៣

១៧-៨-១៩៩៩ -អនុក្រឹត្យលេខ ៨៧៩ អនក្រ.តត ស្តីពីការជូនមេដាយមាសការងារ ១៥៧៥

១៧-៨-១៩៩៩ -អនុក្រឹត្យលេខ ៨៨០ អនក្រ.តត ស្តីពីការជូនមេដាយមាសស្ថាបនាជាតិ ១៥៧៥

១៧-៨-១៩៩៩ -អនុក្រឹត្យលេខ ៨៨១ អនក្រ.តត ស្តីពីការជូនមេដាយប្រាក់ស្ថាបនាជាតិ ១៥៧៥

១៨-៨-១៩៩៩ -អនុក្រឹត្យលេខ ៨៨២ អនក្រ.តត ស្តីពីការដាក់ជូនគ្រឿងឥស្សរិយយសគុណ: ជាតិ ១៥៧៦

១៨-៨-១៩៩៩ -អនុក្រឹត្យលេខ ៨៨៣ អនក្រ.តត ស្តីពីការដាក់ជូនគ្រឿងឥស្សរិយយសការពារជាតិ ១៥៧៨

១៨-៨-១៩៩៩ -អនុក្រឹត្យលេខ ៨៨៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៥៧៨

២៣-៨-១៩៩៩ -អនុក្រឹត្យលេខ ៨៨៥ អនក្រ.តត ស្តីពីការបង្កើតក្រុមបញ្ជាក្នុងកងកម្លាំងអាវុធការពារជាតិ ១៥៧៨


## ២-សេចក្តីសំរេច


១៧-៨-១៩៩៩ -សេចក្តីសំរេចលេខ ៥៦ សសរ ស្តីពីការបង្កើតគណៈកម្មការចំរុះពិភាក្សាជាមួយគណៈប្រតិភូអន្តរក្រសួងផ្នែកព្រំដែន នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ១៥៨០

១៨-៨-១៩៩ -សេចក្តីសំរេចលេខ ៥៧ សសរ ស្តីពីការបង្កើតក្រុមការងារមួយទទួលបន្ទុកសិក្សាគំរោងទីក្រុងពិសេសមួយនៅប្រជុំកោះរុង ១៥៨១

១៩-៨-១៩៩៩ -សេចក្តីសំរេចលេខ ៥៨ សសរ ស្តីពីការតែងតាំងទីប្រឹក្សានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ១៥៨៣

២០-៨-១៩៩៩ -សេចក្តីសំរេចលេខ ៥៩ សសរ ស្តីពីការផ្ទេរសិទ្ធិ ១៥៨៣


## ៣-ផែនការណែនាំ


២០-៨-១៩៩៩ -ផែនការណែនាំលេខ ១១ ផកណក ស្តីពីការរៀបចំពិធីបុណ្យគ្រងរាជសម្បត្តិជាថ្មីរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទិវាប្រកាសរដ្ឋធម្មនុញ្ញ និងពិធីបុណ្យកាន់បិណ្ឌភ្ជុំបិណ្ឌ ១៥៨៥


## IV- ការងារបណ្តាក្រសួង

## ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ យុវនីតិសម្បទា

### ប្រកាស


១៧-៨-១៩៩៩ -ប្រកាសលេខ ២៣៩ សករយ ស្តីពីការបង្កើតគណៈកម្មការ SOS កម្ពុជា ១៥៨៧

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៨៩៩/៥៩

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៩

**ត្រាស់បង្គាប់**

មាត្រា ១ ._ តែងតាំងឯកឧត្តម ស ឈុត ជាទីប្រឹក្សាផ្ទាល់របស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកកិច្ចការធម្មការ និងសាសនា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ ._ បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ ._ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ គាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

***

## ព្រះរាជក្រឹត្យ នស/រកត/០៩៩៩/១៥២

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ .**_ តែងតាំងឯកឧត្តម **ម៉ិច សុខេម** បច្ចុប្បន្ន នាយកខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សាក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ បន្ថែមលើការងារបច្ចុប្បន្ន ដោយមានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២ .**_ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .**_ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

***

## ព្រះរាជក្រឹត្យ នស/រកត/០៩៩៩/១៥៨

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់បទបញ្ញាផ្ទៃក្នុងរបស់រដ្ឋសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សម្ដេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ .**_ តែងតាំងឯកឧត្តម **ឡៀម ថាវី** ជាទីប្រឹក្សាឯកឧត្តម **ងួន ញ៉ិល** អនុប្រធានទី២នៃរដ្ឋសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២ .**_ ប្រធានរដ្ឋសភាជាតិ និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .**_ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

★★★

**ព្រះរាជក្រឹត្យ នស/រកត/០៨៩៩/១៥៩**

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ញាផ្ទៃក្នុងរបស់រដ្ឋសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សម្ដេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ .**_ តែងតាំងឯកឧត្តម **ឡៀម រ៉ុម** ជាទីប្រឹក្សា ឯកឧត្តម **ងួន ញ៉ិល** អនុប្រធានទី២នៃរដ្ឋសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ .**_ ប្រធានរដ្ឋសភាជាតិ និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

***

**ព្រះរាជក្រឹត្យ នស/រកត/០៨៩៩/១៦០**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១ ._ តែងតាំងឯកឧត្តម ឡុង ហ៊ឹម ជាទីប្រឹក្សាឯកឧត្តម ខួន ញឹម អនុប្រធានទី២នៃរដ្ឋសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា ២ ._ ប្រធានរដ្ឋសភាជាតិ និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

***

## ព្រះរាជក្រឹត្យ នស/រកត/០៨៩៩/១៦១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់ទតរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តម អ៊ឹង ទៀងរិទ្ធី ជាទីប្រឹក្សា ឯកឧត្តម ងួន ញ៉ិល អនុប្រធានទី២នៃរដ្ឋសភាជាតិ នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយក ។

មាត្រា ២.- ប្រធានរដ្ឋសភាជាតិ និងអាមាត្យរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

***

# II- ក្រុមប្រឹក្សាធម្មនុញ្ញ

## សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៩

### សេចក្តីសំរេចលេខ ១២ គបធ.សសរ.ច

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៨ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រម ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតប្រធានរដ្ឋសភាស្តីទី លេខ ៥៩២ រស ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩ ស្នើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩

បន្ទាប់ពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

បន្ទាប់ពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមនីតិវិធីដែលមានចែងក្នុងមាត្រា ១១៣ ថ្មីនៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ។
- យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមនីតិវិធីដែលមានចែងក្នុងមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ កថាខ័ណ្ឌទី២ ក្នុងការបញ្ជូនមកឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឲ្យប្រើនូវច្បាប់រៀបចំអង្គការនេះ ។
- យល់ឃើញថា ទម្រង់នៃការតាក់តែង និងអនុម័តច្បាប់រៀបចំអង្គការនេះ ពុំមានអ្វីខុសពីរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារនៃមាត្រា ១.២.៣.៤.៥ និង ៦ នៃច្បាប់រៀបចំអង្គការនេះ ពុំមានចំណុចណាខុស ឬផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

សំរេច

មាត្រា ១ ._ ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ដែលរដ្ឋបានអនុម័តកាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៩៩ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយកាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៩ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ ._ សេចក្តីសំរេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ចាន់ សុក

★★★

# III- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

អនុក្រឹត្យលេខ ៧៤ អនក្រ.បក

ស្ដីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវនិង

អភិវឌ្ឍន៍កសិកម្មកម្ពុជា ជាគ្រឹះស្ថានសាធារណរដ្ឋបាល

រាជរដ្ឋាភិបាល

បានឃើញព្រះរាជក្រមអនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណរដ្ឋបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៩

សម្រេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

មាត្រា ១ ._ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា សរសេរកាត់ វ.ស.អ.ក.ក ជាគ្រឹះស្ថានសាធារណរដ្ឋបាលស្ថិតនៅក្រោមបទបញ្ញត្តិ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណរដ្ឋបាលនិងអនុក្រឹត្យនេះព្រមទាំងបទបញ្ញត្តិក្នុងមួយនិងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត នាថ្ងៃក្រោយ ។

មាត្រា ២ ._ វ.ស.អ.ក.ក មាននីតិបុគ្គលភាព និងស្វ័យភាពហិរញ្ញវត្ថុ ។

មាត្រា ៣ ._ ក្នុងក្របខ័ណ្ឌជាគ្រឹះស្ថានសាធារណរដ្ឋបាល វ.ស.អ.ក.ក ទទួលពីរដ្ឋនូវអំណាច និងភារកិច្ចទាំងឡាយ ដើម្បីបំពេញនូវភារកិច្ចដូចតទៅ ៖

៣.១- ដឹកនាំ និងសំរបសំរួលសកម្មភាពស្រាវជ្រាវ និងពិសោធន៍ សំដៅជំរុញការអភិវឌ្ឍន៍កសិកម្ម

៣.២- ធ្វើការសិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយអំពីវិទ្យាសាស្ត្របច្ចេកទេស និងសេដ្ឋកិច្ចកសិកម្ម មានជាអាទិ៍ ៖

៣.២.១-បច្ចេកទេសប្រើប្រាស់ដីកសិកម្ម ការប្រើប្រាស់ជីគ្រប់ប្រភេទ ចូលរួមការកែលំអ និងថែរក្សានិរន្តរភាពគុណភាពដី ។

៣.២.២.-បង្កើត និងបន្សាំពូជថ្មីៗ ប្រកបដោយសក្តានុពលសេដ្ឋកិច្ចខ្ពស់ ទិន្នផលខ្ពស់ធន់នឹងជំងឺ នឹងសត្វល្អិតចង្រៃ និងមានគុណភាពសមស្របតាមតំរូវការ របស់ទីផ្សារ និងការបរិភោគ ។

៣.២.៣-អភិវឌ្ឍន៍បច្ចេកទេសការពារដំណាំ មានការប្រើប្រាស់ថ្នាំកសិកម្មផ្សេងៗការប្រើប្រាស់វិធានការចំរុះ “ មេកានិក ជីវសាស្ត្រ ថ្នាំ ” បង្កើនប្រសិទ្ធភាព ក្នុងកិច្ចការពារដំណាំប្រឆាំងសត្វល្អិតចង្រៃផ្សេងៗផង បន្ថយគ្រោះថ្នាក់ចំពោះសុខភាព ពលករកសិកម្ម និងអ្នកបរិភោគផង និងចូលរួមថែរក្សាតុល្យភាព នៃបរិស្ថានធម្មជាតិផង ។

៣.២.៤-ការប្រើប្រាស់គ្រឿងយន្ត និងឧបករណ៍កសិកម្មទំនើបៗ ឈានទៅអភិវឌ្ឍន៍ឧស្សាហូបនីយកម្មជាជំហានៗ ក្នុងវិស័យកសិកម្ម ។

៣.២.៥-ប្រព័ន្ធកសិកម្មចំរុះចូលរួមបង្កើន និងធានាសុវត្ថិភាពប្រាក់ចំណូល សំដៅលើកស្ទួយកំរិតជីវភាពរបស់កសិករ ។

៣.៣-ផ្តល់សេវាគាំទ្រដល់ការកសាង និងការអនុវត្តន៍គំរោងការអភិវឌ្ឍន៍កសិកម្មផ្សេងៗ តាមការសិក្សា សិក្សាលើលក្ខណៈវិនិច្ឆ័យ ការតាមដាន និងការវាយតំលៃផ្នែកបច្ចេកទេស និងសេដ្ឋកិច្ច សមស្របទៅនឹងតម្រូវការរបស់ស្ថាប័ន ឬ បុគ្គលពាក់ព័ន្ធ ជាពិសេសកសិករ ។

៣.៤-អភិវឌ្ឍន៍ធនធានមនុស្ស សំរាប់វិស័យកសិកម្មតាមរយៈការរៀបចំ សិក្ខាសាលា ទស្សនកិច្ចសិក្សា កម្មសិក្សា និងអង្គប្រជុំផ្សេងៗ ទៀត ។ល ។

៣.៥-ធ្វើទំនាក់ទំនងជាមួយបណ្តាស្ថាប័នស្រាវជ្រាវ លើសកលលោក រៀបចំ និងចូលរួមកិច្ចប្រជុំជាមួយអង្គការអន្តរជាតិនានា ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងផ្លាស់ប្តូរបទពិសោធ និងព័ត៌មានបច្ចេកវិទ្យាសាស្ត្រសេដ្ឋកិច្ចតាមតំរូវការ និងការចាំបាច់ ។

## ជំពូកទី ២
## ការដឹកនាំ និងការគ្រប់គ្រង
### ផ្នែកទី ១
### អង្គការសំរេចរបស់វិទ្យាស្ថាន

**មាត្រា ៤ ._** វ.ស.អ.ក.ក ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិអំណាចទូលំទូលាយ ដើម្បីបំពេញបេសកកម្មក្នុងនាម វ.ស.អ.ក.ក ក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិនៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

មាត្រា ៥ ._

៥.១._ ក្រុមប្រឹក្សាភិបាល មានសមាជិក ១១ រូប ដែលមានសមាសភាពដូចតទៅ ៖

- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប ជាប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១រូប ជាសមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូប ជាសមាជិក
- តំណាងក្រសួងបរិស្ថាន ១រូប ជាសមាជិក
- តំណាងក្រសួងអប់រំយុវជននិងកីឡា ១រូប ជាសមាជិក
- តំណាងក្រសួងអភិវឌ្ឍន៍ជនបទ ១រូប ជាសមាជិក
- តំណាងក្រសួងធនធានទឹក និងឧតុនិយម ១រូប ជាសមាជិក
- តំណាងនាយកដ្ឋានក្សេត្រសាស្ត្រ ១រូប ជាសមាជិក
- នាយកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ១រូប ជាសមាជិក
- ឯកជនដែលមានចំណេះដឹងនិងបទពិសោធផ្នែកកសិកម្ម ១រូប ជាសមាជិក
- តំណាងនិយោជិត របស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ១រូប ជាសមាជិក ស្វ័យប្រវត្តិ

៥.២- ប្រធានក្រុមប្រឹក្សាភិបាល និងសមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងដោយអនុក្រឹត្យសំរាប់អាណត្តិ ០៣ ( បី ) ឆ្នាំ ស្នើដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់ក្រសួង ឬ អាជ្ញាធរដែលខ្លួនតំណាងឲ្យ ។

អាណត្តិនេះ អាចបញ្ចប់គ្រប់ពេលវេលា ដោយអនុក្រឹត្យតាមសំណើនៃក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងនោះ ។

៥.៣.- តំណាងនិយោជិត ត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមបុគ្គលិក **វ.ស.អ.ក.ក** ។

**មាត្រា ៦ ._** សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសរើសក្នុងចំណោម មន្ត្រីដែលសេវកម្ម ធ្លាប់បានបំរើការងារយ៉ាងតិច ០៥ ( ប្រាំ ) ឆ្នាំ ឬជាឯកជនដែលមានអាយុមិនលើសពី ៦៥ ឆ្នាំ និងមានបទពិសោធការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលទទួលការផ្តន្ទាទោសពីតុលាការ ។

**មាត្រា ៧ ._**

៧.១._ ប្រធានក្រុមប្រឹក្សាភិបាល មានតួនាទីកោះប្រជុំ និងកំណត់របៀបវារៈនៃអង្គប្រជុំ របស់ក្រុមប្រឹក្សាភិបាល ព្រមទាំងធានារៀបរយ នៃកិច្ចប្រជុំនេះឲ្យបានល្អប្រសើរ ។

៧.២._ ក្រុមប្រឹក្សាភិបាលអាចអញ្ជើញឯកជននៅក្នុង ឬក្រៅវិទ្យាស្ថាននេះ ដែលមានបទពិសោធលើវិស័យកសិកម្ម រុក្ខកម្ម ផលិតកម្ម និងបសុព្យាបាល ជលផល សេដ្ឋកិច្ចកសិកម្ម ឧស្សាហកម្ម និងតំណាងអ្នកផ្តល់ជំនួយចូលរួម ក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។

ឥស្សរជនទាំងនេះមានសិទ្ធិផ្តល់មតិ តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ ។

មាត្រា ៨ ._

[illegible]ក្រុមប្រឹក្សាភិបាលមានភារៈ [illegible] ដឹកនាំ ចាត់ចែង [illegible] ធ្វើការត្រួតពិនិត្យ [illegible] ការអភិវឌ្ឍ [illegible] ក្រុមប្រឹក្សាភិបាល

-[illegible] និងសំរេចលើ[illegible]ការអភិវឌ្ឍរបស់ ទ.ស.អ.គ.ក ក្រោមការ[illegible]ការគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាល ។

-ពិនិត្យ និងសំរេចលើថវិកា និងចំណាយជាប្រចាំ[illegible]ទាំងមូល ក្នុងថវិកា[illegible]របស់ ទ.ស.អ.គ.ក ។

-ពិនិត្យ និងសំរេចលើរបាយការណ៍ត្រួតពិនិត្យ និង[illegible]ហិរញ្ញវត្ថុប្រចាំឆ្នាំ

-[illegible]ការរៀបចំរចនាសម្ព័ន្ធ ព្រមទាំងការបែងចែកភារកិច្ចជាទូទៅ ដល់អង្គភាពក្រោមឱវាទ ។

-កំណត់នូវរបបជ្រើសរើសការតម្លើងឋានន្តរសក្តិ ការផ្តល់លាភការដល់បុគ្គលិក ទ.ស.អ.គ.ក ដោយមិនប៉ះពាល់ដល់បទបញ្ញត្តិច្បាប់ ឬបទបញ្ជាផ្ទៃក្នុងដែលអនុវត្ត ចំពោះភ្នាក់ងារមុខងារសាធារណៈ

-សំរេចលើក្របខ័ណ្ឌចំនួនបុគ្គលិក ដែលអនុញ្ញាតសំរាប់ ទ.ស.អ.គ.ក

-សំរេចលើកិច្ចសន្យា ស៊ីពីលទ្ធកម្ម

-ធ្វើការវាយតំលៃតាមចន្លោះពេលទៀងទាត់ លើកំរិតលទ្ធផល សំរេចបានតាមគោលដៅកំណត់ ដោយ ទ.ស.អ.គ.ក ហើយកំណត់នូវវិធានការកែតម្រូវដើម្បីអនុវត្ត ។

មាត្រា ៩ ._

លាភការរបស់ក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់នាយកវិទ្យាស្ថាន ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

មាត្រា ១០ ._

១០.១._ ក្រុមប្រឹក្សាភិបាលនៃ ទ.ស.អ.គ.ក ត្រូវធ្វើការប្រជុំនៅពេលណា ដែលផលប្រយោជន៍របស់ ទ.ស.អ.គ.ក តម្រូវ និងត្រូវធ្វើការប្រជុំយ៉ាងតិចមួយត្រីមាសម្តង តាមការអញ្ជើញរបស់ប្រធាន ឬតាមសំណើរបស់សមាជិកចំនួន០៤ (បួន) នាក់ឡើងទៅ ឬតាមការស្នើសុំពីនាយកវិទ្យាស្ថាន ទ.ស.អ.គ.ក ។

ក្នុងករណីប្រធានមានធុរៈ ត្រូវបោះឆ្នោតជ្រើសរើសសមាជិកណាម្នាក់ ក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ ។

ប្រធានអង្គប្រជុំ ត្រូវជ្រើសរើសលេខាធិការ នៃអង្គប្រជុំ ០១ ( មួយ ) រូប ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល ។ លេខាធិការនេះគ្មានសិទ្ធិបោះឆ្នោតទេ ។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវចូលរួមប្រជុំក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែគ្មានសិទ្ធិបោះឆ្នោតទេ ។

របៀបវារៈ ព្រមទាំងឯកសារទាំងឡាយ ត្រូវផ្ញើជូនគ្រប់សមាជិក នៃក្រុមប្រឹក្សាភិបាល និងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានចែងក្នុងអនុក្រឹត្យនេះយ៉ាងតិច ១០ ថ្ងៃមុន ថ្ងៃប្រជុំ ។

១០.២._ ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចនឹងយកជាការបាន លុះត្រាតែមានសមាជិកវត្តមាន ចំនួនលើសពី ៥០ ( ហាសិប ) ភាគរយ នៃសមាជិកទាំងអស់ ។ សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងឲ្យមកប្រជុំជំនួសខ្លួនបានឡើយ ។ បើសិនសំលេងឆ្នោតមិនគ្រប់ចំនួនទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំម្តងទៀត យ៉ាងយូរ ១៥ ( ដប់ប្រាំ ) ថ្ងៃក្រោយ ថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះ មិនចាំបាច់ស្នើរសុំអោយមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈ នៃការអញ្ជើញប្រជុំលើកទីមួយ ។ សមាជិកវត្តមាន ត្រូវចុះហត្ថលេខាលើបញ្ជីវត្តមានមួយ ។ សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល អាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំលេងភាគច្រើន នៃសមាជិកវត្តមាន ។

ក្នុងករណីមានសំលេងស្មើគ្នា សំលេងប្រធានអង្គប្រជុំ ចាត់ទុកជាឧត្តមានុភាព ។

១០.៣._ សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ ដែលរក្សាទុកនៅទីស្នាក់ការរបស់វិទ្យាស្ថាន និងត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ សមាជិកវត្តមាន និងលេខាធិការអង្គប្រជុំ ។ កំណត់ហេតុនេះត្រូវបញ្ជាក់អត្ថន័យ នៃការពិភាក្សាឲ្យបានច្បាស់លាស់ និងត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងផ្ញើជូនក្រសួងពាក់ព័ន្ធយ៉ាងយូរ ១០ ថ្ងៃក្រោយពេលប្រជុំ ។

## ជំពូកទី ២

## អង្គការប្រតិបត្តិរបស់វិទ្យាស្ថាន

**មាត្រា ១១ ._**

វ.ស.អ.ក.ក ត្រូវគ្រប់គ្រងដោយនាយកមួយរូប មានតួនាទីជានាយកប្រតិបត្តិ ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ១២ ._**

១២.១._ នាយក វ.ស.អ.ក.ក មានសិទ្ធិពេញលេញ ដើម្បីគ្រប់គ្រងអនុវត្តការងារ ដែលមានចែងក្នុងច្បាប់ និង អនុក្រឹត្យនេះ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ច របស់ក្រុមប្រឹក្សាភិបាល ។ នាយកមានភារកិច្ច ៖

-រៀបចំ ការងារអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។

-ទទួលខុសត្រូវអនុវត្តសេចក្តីសំរេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់ឲ្យដំណើរការនូវគោលការណ៍ដែលកំណត់ដោយក្រុមប្រឹក្សាភិបាលនេះ ។

-រៀបចំថវិកាប្រចាំឆ្នាំរបស់ វ.ស.អ.ក.ក ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យសំរេច ។

-ធ្វើរបាយការណ៍ប្រចាំឆ្នាំលើភាពសកម្មភាព ត្រួតពិនិត្យលើគណនីហិរញ្ញវត្ថុ ប្រចាំឆ្នាំ ហើយដាក់ឯកសារទាំងនេះ ជូនក្រុមប្រឹក្សាភិបាលពិនិត្យសម្រេច ។

-ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើការកិច្ចរបស់អង្គភាពក្រោមឱវាទ ។

-បំពេញភារកិច្ចតំណាងឲ្យ ទ.ស.អ.ក.ភ ក្នុងកិច្ចការទំនាក់ទំនងបុគ្គលិក ដែលស្ថិតនៅក្រោមការ ក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពតាមលក្ខន្តិកៈ ស្ដីពីការគ្រប់គ្រងបុគ្គលិក ។

-បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់របស់ ទ.ស.អ.ក.ភ ។

-តាំងតែងលើការងារពាណិជ្ជកម្ម និងចុះបញ្ជីលេខាលើអនុសញ្ញាផ្សេងៗ ដោយអនុលោមទៅតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្ដីពីការបែងចែកសិទ្ធិអំណាចនិងទៅតាមបទបញ្ញាផ្ទៃក្នុង ព្រមទាំងបទបញ្ញត្តិដទៃទៀត ស្ដីពីបញ្ហានេះ ។

ជារួមគឺបំពេញភារកិច្ចរដ្ឋបាល និងគ្រប់គ្រងទាំងឡាយ ដែលត្រូវបានប្រគល់ទៅតាមបទបញ្ញាផ្ទៃក្នុងរបស់ ទ.ស.អ.ក.ភ និងតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

១២.២._ នាយក ទ.ស.អ.ក.ភ ជាតំណាងរបស់វិទ្យាស្ថាន ក្នុងការទំនាក់ទំនងជាមួយតតិយជន ។

១២.៣._ នាយក ទ.ស.អ.ក.ភ ត្រូវស្នើទៅក្រុមប្រឹក្សាភិបាល សុំតែងតាំង នាយករងម្នាក់ទៀត ដើម្បីជាជំនួយការរបស់ខ្លួន ។

## ផ្នែកទី ៣

## បុគ្គលិករបស់ ទ.ស.អ.ក.ភ

**មាត្រា ១៣ ._**

១៣.៣._ បុគ្គលិកអចិន្ត្រៃយ៍របស់ ទ.ស.អ.ក.ភ រួមមានមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ អតីតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬជ្រើសរើសតាមសំណើរបស់នាយក ទ.ស.អ.ក.ភ ។ មន្ត្រីទាំងនេះ ត្រូវបានរក្សាទុកនូវក្របខ័ណ្ឌប្រាក់បៀវត្ស និងប្រាក់ពិសេសផ្សេងៗ ដែលបានកំណត់ដោយមុខងារសាធារណៈ ពីអង្គភាពដើមរបស់ខ្លួន ។

១៣.២._ វិទ្យាស្ថានអាចជ្រើសរើសភ្នាក់ងារជាប់កិច្ចសន្យាជំនួយការ និងបុគ្គលិកអណ្ដែត ។ ភ្នាក់ងារទាំងនេះត្រូវស្ថិតនៅក្រោមវិធានបញ្ញត្តិ នៃបទបញ្ញាផ្ទៃក្នុង និងតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ស្ដីពីការងារ ។

១៣.៣._ បុគ្គលិក ទ.ស.អ.ក.ភ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ញា ស្ដីពីបុគ្គលិក សម្រេចដោយក្រុមប្រឹក្សាភិបាល ។ ក្រុមប្រឹក្សាភិបាល កំណត់ប្រាក់ចំណែកលើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងរបបនៃការទូទាត់ផ្សេងៗដែលមានចែង នៅក្នុងបទបញ្ញាផ្ទៃក្នុង ។

## ជំពូកទី ៤
## ទ្រព្យសម្បត្តិរបស់ ទ.ស.អ.ក.គ

មាត្រា ១៤ ._

១៤.១._ ទ.ស.អ.ក.គ ទទួលដើមទុនដំបូងពីរដ្ឋនូវអចលនវត្ថុដូចតទៅ ៖

-ដីជាទីតាំង ទ.ស.អ.ក.គ មានផ្ទៃដី ៧០ ( ចិតសិប ) ហិកតា ស្ថិតនៅសង្កាត់ប្រទះឡាង ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ដូចមានផែនទីបញ្ជាក់ទីតាំង ភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

-អាគារទីស្នាក់ការ និងអាគារផ្សេងៗ ទៀតដែលស្ថិតនៅក្នុងដីជាទីតាំង ទ.ស.អ.ក.គ នោះ ។

១៤.២._ ក្រៅពីអចលនទ្រព្យខាងលើ ទ.ស.អ.ក.គ ត្រូវបានទទួលនូវចលនទ្រព្យ និងអចលនទ្រព្យផ្សេងៗ ដែលកំពុងប្រើប្រាស់ពេលបច្ចុប្បន្ន ។

១៤.៣._ អចលនទ្រព្យ និងចលនទ្រព្យទាំងអស់របស់ ទ.ស.អ.ក.គ នឹងមានចែងលំអិតក្នុងបញ្ជីសារពើភ័ណ្ឌ ។

១៤.៤._ វិទ្យាស្ថាន អាចទិញ-លក់ ចលនទ្រព្យនិងអចលនទ្រព្យចាំបាច់ សំរាប់ដំណើរការរបស់ខ្លួន ។

## ជំពូកទី ៥
## ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់ ទ.ស.អ.ក.គ

មាត្រា ១៥ ._

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យនៃ ទ.ស.អ.ក.គ ត្រូវប្រព្រឹត្តស្របតាមគោលការណ៍នៃគណនេយ្យសាធារណៈ ដូចមានចែងក្នុងមាត្រា ១២២ នៃអនុក្រឹត្យលេខ ៨២ អនក្រ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ ។

មាត្រា ១៦ ._

១៦.១._ ប្រធាន ឬនាយក ទ.ស.អ.ក.គ ជាអាណាប័កដើមខ្សែរបស់វិទ្យាស្ថាន ។ ក្នុងន័យនេះ ដើម្បីអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់វិទ្យាស្ថាន ប្រធាន ឬនាយក ទ.ស.អ.ក.គ ត្រូវមានភារកិច្ច ៖

-ពិនិត្យប្រាក់ និងទូទាត់ចំណូល

-ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ

១៦.២._ អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិ ឬផ្តល់ការចាត់ផ្ទេរសិទ្ធិ ឬបង្កើតដោយមានការព្រមព្រៀងពីគណនេយ្យករនូវរដ្ឋទេយ្យចំណូល ចំណាយប្រាក់ទាន់ ។

មាត្រា ១៧ ._

១៧.១._ ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុង របស់វិទ្យាស្ថានក្រោមការទទួលខុសត្រូវផ្ទាល់របស់ភ្នាក់ងារគណនេយ្យ ។ ភ្នាក់ងារគណនេយ្យ

នេះត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ ។ ភ្នាក់ងារគណនេយ្យនេះ ត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងឋានៈជាអ្នកពិគ្រោះយោបល់ តែគ្មានសំលេងឆ្នោតឡើយ ។

១៧.២._ ភ្នាក់ងារគណនេយ្យត្រូវទទួល ៖

-ប្រមូលចំណូល

-បើកប្រាក់ចំណាយ

-រក្សាទុក និងចាត់ចែងប្រើប្រាស់នូវ មូលនិធិ និងធនធានរបស់ វ.ស.អ.ក.ក

-រក្សាទុកលិខិតយុត្តិការណ៍ និងកាន់កាប់បញ្ជីគណនេយ្យ ។

១៧.៣._ ភ្នាក់ងារគណនេយ្យ អាចផ្ទេរសិទ្ធិខ្លះ ទៅឲ្យអាជ្ញានុការីរបស់ខ្លួន ។

**មាត្រា ១៨ ._**

១៨.១._ ប្រភពធនធានរបស់ វ.ស.អ.ក.ក រួមមាន ៖

-ធនធានដំបូង ដែលរដ្ឋផ្តល់ឲ្យវិទ្យាស្ថាន នៅពេលផ្តើមបង្កើតដំបូង

-ឧបត្ថម្ភធនសំរាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន ដែលមានចែងក្នុងថវិការដ្ឋ

-អំណោយ ជំនួយ និងអច្ច័យទាន ដែលវិទ្យាស្ថានបានទទួល

-ប្រាក់ខ្ចីបុលដោយវិទ្យាស្ថានផ្ទាល់ និងប្រាក់ដែលរដ្ឋខ្ចីឲ្យវិទ្យាស្ថាន

-ផលនៃការងារ និងកំរៃនៃការផ្តល់សេវាផ្សេងៗ ដោយវិទ្យាស្ថាន

-កំរៃនៃទ្រព្យសម្បត្តិរបស់វិទ្យាស្ថាន និងចំណូលនៃការលក់ទ្រព្យសម្បត្តិទាំងនោះ ឬការជួលចលនវត្ថុ ឬ អចលនវត្ថុរបស់ វ.ស.អ.ក.ក

-កំរៃនៃទ្រព្យសម្បត្តិ ដែលបានប្រគល់អោយវិទ្យាស្ថាន ។

១៨.២._ ចំណូល និងចំណាយជាប្រចាំ ព្រមទាំងមូលធនរបស់ វ.ស.អ.ក.ក ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់វិទ្យាស្ថាន ។ ក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថាន ត្រូវចែងអំពីបែបបទនៃការរៀបចំការចាត់ចែង និងអនុវត្តថវិកា ។ សេចក្តីសំរេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាលទាក់ទងដល់ទំរង់បែបបទនៃការរៀបចំ ការចាត់ចែង និងអនុវត្តថវិកា ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៨.៣._ ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្សែនៃ វ.ស.អ.ក.ក ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដែលត្រូវធ្វើការសំរេចយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែកញ្ញា ក្នុងឆ្នាំនីមួយៗ ។ ថវិកាត្រូវតែធ្វើឲ្យមានលំនឹងរវាងចំណូល និង ចំណាយ ។

**មាត្រា ១៩ ._**

១៩.១._ ការងារគណនេយ្យរបស់ វ.ស.អ.ក.ក រួមមាន ៖

-គណនេយ្យទូទៅត្រូវកាន់កាប់ជាគណនេយ្យទ្វេភាគ ដែលចែងអំពីប្រតិបត្តិការថវិការគនាគារ និងប្រតិបត្តិការដែលអនុវត្តជាមួយអតិថិជន
-គណនេយ្យ អសង្ហារឹម រូបធាតុ និងគណនេយ្យតំលៃ
-គណនេយ្យវិភាគ ប្រសិនបើជាការចាំបាច់

គណនេយ្យរបស់វិទ្យាស្ថានត្រូវ ៖

១-គោរពតាមវិធានដែលកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២-គោរពតាមប្លង់គណនេយ្យ របស់វិទ្យាស្ថានដែលសំរេចដោយក្រុមប្រឹក្សាភិបាល ។ ប្លង់គណនេយ្យនេះ ត្រូវបានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-១៩.២._ គណនីហិរញ្ញវត្ថុប្រចាំឆ្នាំរបស់វិទ្យាស្ថាន ត្រូវរៀបចំដោយគណនេយ្យករ ហើយត្រូវដាក់ដោយអាណាប័កដើមខ្មែរ ភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសំរេចលើឯកសារ ទាំងនោះយ៉ាងយូរ ០៣ ( បី ) ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ ។

មាត្រា ២០ ._

មូលនិធិរបស់ វ.ស.អ.ក.ក គឺជាមូលនិធិសាធារណៈ ដែលត្រូវដាក់ចូលក្នុងគណនីមួយនៅរតនាគារជាចាំបាច់ លើកលែងតែមានលិខិតបញ្ញត្តិ ដែលត្រូវមានការយល់ព្រមតាមប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ៦

## របបសារពើពន្ធនៃ វ.ស.អ.ក.ក

មាត្រា ២១ ._

លើកលែងតែមានលិខិតបញ្ញត្តិដែលចែងដោយច្បាប់ វ.ស.អ.ក.ក ត្រូវស្ថិតនៅក្រោមនីតិរបបចំពោះរបបសារពើពន្ធដូចដែលត្រូវបានអនុវត្តន៍ លើអង្គភាពនានារបស់រដ្ឋ ។

## ផ្នែកទី ៧

## លទ្ធកម្មរបស់ វ.ស.អ.ក.ក

មាត្រា ២២ ._

ការសំរេច ការអនុវត្តន៍ និងការត្រួតពិនិត្យលើលទ្ធកម្មរបស់ វ.ស.អ.ក.ក ត្រូវគ្រប់គ្រងតាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ៦០ អនក្រ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីលទ្ធកម្មសាធារណៈ និងបទបញ្ញាដទៃទៀតពាក់ព័ន្ធនឹងបញ្ហានេះ ។

## ផ្នែកទី ៣

## អាណាព្យាបាលលើ វ.ស.អ.ក.ក

មាត្រា ២៣ ._

វ.ស.អ.ក.ក ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រោមអាណាព្យាបាល ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២៤ ._**

២៤.១._ **ទ.ស.ឆ.ក.ភ** ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដូចតទៅ៖

-កំណត់ហេតុ នៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល

-ផែនការអភិវឌ្ឍន៍របស់វិទ្យាស្ថាន

-ថវិកាប្រចាំឆ្នាំ

-របាយការណ៍ ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ

២៤.២._ ឯកសារទាំងនេះ ត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួល ក្នុងរយៈពេលមិនអោយហួសពី ១៥ថ្ងៃ ។

**ផ្នែកទី ១**

**អាណាព្យាបាលបច្ចេកទេស**

**មាត្រា ២៥ ._**

២៥.១._ ក្នុងរយៈពេល ១៥ (ដប់ប្រាំថ្ងៃ) ក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាល នាយក **ទ.ស.ឆ.ក.ភ** ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍន៍ និងគំរោងថវិកាប្រចាំឆ្នាំដើម្បីសុំការយល់ព្រម ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានពេល១ (មួយ) ខែ គិតពីថ្ងៃដែលបានទទួលឯកសារ ត្រូវផ្តល់យោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេស មានពេល២ (ពីរ) ខែគិតចាប់ពីថ្ងៃដែលបានទទួលឯកសារ ដែលបញ្ជូនដោយនាយក ដើម្បីសំរេចផ្តល់ការយល់ព្រមលើឯកសារទាំងនោះ ។

២៥.២._ លិខិតយល់ព្រមត្រូវចុះហត្ថលេខាត្រឹមត្រូវ ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង ហើយត្រូវផ្ញើជូនទៅនាយក **ទ.ស.ឆ.ក.ភ** ដោយមានចំលងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ នាយក **ទ.ស.ឆ.ក.ភ** ត្រូវបញ្ជូនពត៌មាននេះ ទៅអោយក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

**២៧.២._** ការព្យួរការងារ ឬ ការផ្អាកទុកនេះត្រូវតែធ្វើឡើងដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានបញ្ជាក់ពីមូលហេតុ តាមសំណើផ្ទាល់ខ្លួនរបស់ប្រធានអង្គភាព ឬ តាមការស្នើសុំពីភាគីនានាដែលពាក់ព័ន្ធ ។ ការព្យួរការងារ ឬ ការផ្អាកទុកនូវសេចក្តីសំរេចនេះ ត្រូវជូន

ដំណឹងជាលាយលក្ខណ៍អក្សរដល់នាយក **ទ.ស.អ.គ.ក** ហើយនាយកត្រូវជូនពត៌មានបន្តទៅ ក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលដ៏ឆាប់បំផុត ។

**មាត្រា ២៨ ._**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចចាត់ចែងឡើងនូវការផ្ទៀងផ្ទាត់អធិការកិច្ច ឬ ការត្រួតពិនិត្យការងារក្នុងវិទ្យាស្ថាន ក្នុងករណីដែលយល់ថា ជាការចាំបាច់ស្របតាមល័ក្ខខ័ណ្ឌ និង បែបបទដែលមានចែងក្នុងច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន ។

## ផ្នែកទី ២
## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា ២៩ ._**

២៩.១._ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល នាយក **ទ.ស.អ.គ.ក** ត្រូវផ្ញើរបាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានពេល០១ ( មួយ ) ខែ គិតចាប់ពីថ្ងៃទទួលឯកសារ ដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានពេល ០២ (ពីរ) ខែគិតចាប់ពីថ្ងៃទទួលឯកសារ ដែលបញ្ជូនមកដោយនាយក **ទ.ស.អ.គ.ក** ដើម្បីផ្តល់ការយល់ព្រមលើឯកសារទាំងនេះ ។

២៩.២._ លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ អ្នកតំណាង ត្រូវផ្ញើទៅនាយក **ទ.ស.អ.គ.ក** ដោយមានចំលងជូនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ នាយក **ទ.ស.អ.គ.ក** ត្រូវជូនពត៌មាននេះដល់ក្រុមប្រឹក្សាភិបាលអោយឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនបានឆ្លើយតបក្នុងរយៈពេលដូចបានកំណត់ខាងលើ របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានយោបល់ជំទាស់លើរបាយការណ៍ខាងលើ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឲ្យបានឆាប់រហ័សបំផុតដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនោះ ។

របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចត្រូវគេយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់ដែលលើកឡើង ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំទាន់ត្រូវបានដោះស្រាយនៅឡើយនោះ ។

មាត្រា ៣០ ._

សេចក្ដីសម្រេចដូចមានរៀបរាប់ខាងក្រោមនេះ របស់ក្រុមប្រឹក្សាភិបាល នាយក ទ.ស.អ.ក.ក ត្រូវដាក់សុំការអនុញ្ញាតជាមុនពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការផ្ដល់យោបល់ពី មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ រួមមាន ៖

-សេចក្ដីសម្រេចស្ដីពីការលក់ ឬ ផ្ទេរសិទ្ធិអចលនទ្រព្យ

-សេចក្ដីសម្រេចស្ដីពីការលើកលែងឥណទានទារ ដែលមានទឹកប្រាក់លើសពីការកំណត់ របស់ប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សេចក្ដីសម្រេច ស្ដីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសំរាប់ការធានា ឬ លើខិតគោរឡើងស្មានេះ ។

មាត្រា ៣១ ._

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុម្នាក់ ប្រចាំ ទ.ស.អ.ក.ក ដោយមានការឯកភាព ពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ មន្ត្រីនេះមានភារកិច្ចធ្វើការត្រួតពិនិត្យជាមុន និងជាក្រោយលើ ទ.ស.អ.ក.ក តាមក្រោមអនុក្រឹត្យលេខ ៩១ អនក្រ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតឡើងនូវការត្រួតពិនិត្យ ហិរញ្ញវត្ថុ លើការចំណាយថវិកាតាមក្រសួង រដ្ឋភាពមូលដ្ឋាន តាមបណ្ដាខេត្ត-ក្រុង និងតាមអង្គភាពសាធារណៈដែលមានលក្ខណៈរដ្ឋបាល ។

មាត្រា ៣២._

៣២.១._ ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែនៃ ទ.ស.អ.ក.ក ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣២.២._ ការគ្រប់គ្រងរបស់គណនេយ្យករ ត្រូវស្ថិតក្រោមការត្រួតពិនិត្យ របស់គណនេយ្យករកណ្ដាល នៃធនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ ។

៣២.៣._ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់តែងធ្វើការផ្ទៀងផ្ទាត់ អធិការកិច្ច ឬការត្រួតពិនិត្យលើទីទូទាត់នានាពេលដែលយល់ថា ចាំបាច់ស្របតាមបេក្ខន័យ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន ។

## ជំពូកទី ៩

## អវសានបញ្ញត្តិ

មាត្រា ៣៣ ._

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣៩ .

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខា
គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
ហត្ថលេខា
ឈាន សុខ

★★★

## ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

## ប័ណ្ណសំគាល់សិទ្ធិ
## កាន់កាប់ប្រើប្រាស់ដីធ្លី

ភូមិ .................

ឃុំ ព្រែកឡាង

***

### យោង លិខិត :

-លេខ ៩៩៥ សរណៈ.កស ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។
-លេខ ១២៩៦ សរណៈ.កស ចុះថ្ងៃទី២៣ សីហា ឆ្នាំ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។
-លេខ ៥៣៣៩ កសក.អរប ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-លេខ ៣៩៥៥ ធ.គណ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៦ របស់សាលាក្រុងភ្នំពេញ ។

### ចំណាំ

-ម្ចាស់ដី ឬអ្នកបន្តសិទ្ធិ " អ្នកទិញ " ត្រូវគោរពតាមការអភិវឌ្ឍន៍របស់ទីក្រុងនាពេលអនាគត ដោយគ្មានទាមទារសំណងអ្វីឡើយ

ជ.ប្រធាននាយកដ្ឋាន សុរិយោដី និង គ.ប
ការិយាល័យសុរិយោដីក្រុងភ្នំពេញ
ប្រធាន
ហត្ថលេខានិងត្រា
ឈួន សុធី

គណៈកម្មាធិការប្រជាជន
ក្រុងភ្នំពេញ
ស្រុក ដង្កោ
លេខ DT 003 ឆ XII

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឈ្មោះអ្នកកាន់កាប់ដី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ភេទ........................... អាយុ.................................សញ្ជាតិ................................

ទីលំនៅបច្ចុប្បន្ន ......................................................................................

.......................................................................................................

ចំនួនសមាជិកគ្រួសារ....................................................................................

ទីកន្លែងដី ភូមិ ឃុំពងទឹក និង ឃុំ ប្រទះឡាង

ស្រុក ដង្កោ ខេត្ត រាជធានីភ្នំពេញ

ប្រភេទដី ( ១ ) ស្រែ ........................................

ទំហំដី ( ២ ) ៧០ ហិកតា ០០ អារ ០ សង្ទីអារ ..............................

ដង្កោ ថ្ងៃទី ១៣ ខែ ១២ ឆ្នាំ១៩៨៦

បានឃើញ
ប្រធានគណៈកម្មាធិការប្រជាជនស្រុក
ហត្ថលេខា និងត្រា
គ្រួច ផាន

ប្រធានការិយាល័យកសិកម្មស្រុក
ប្រធានការិយាល័យភូមិបាលខ័ណ្ឌដង្កោ
ហត្ថលេខា និងត្រា
គុល ណាត

***

ចំនួនប្លង់ដី ( ៣ ) ទ្រព្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ




មាត្រដ្ឋាន : ១០.០០០

---

(១-)ដីសង់លំនៅឋាន ឬដីស្រែ ឬដីចំការ

(២-)គិតជាម៉ែត្រក្រឡា ឬ ហិកតា

(៣-)មាត្រដ្ឋាន១/៥០០០-១/១០០ អាស្រ័យទំហំដី ធំ ឬតូចនិងបញ្ជាក់ឈ្មោះ អ្នកកាន់កាប់ដីជាប់គ្នា

ប្លង់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ( ៧០ហិកតា )

★★★

## អនុក្រឹត្យលេខ ៧៥ អនក្រ.បក

## ស្តីពីបែបបទសំរាប់អនុវត្តចំពោះ ការអនុញ្ញាតអោយជនបរទេស មិនមែនអន្តោប្រវេសន្ត ចូល ចេញ និង ស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គនាថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៩

**សម្រេច**

**ជំពូកទី ១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា ១._**

អនុក្រឹត្យនេះកំណត់អំពីរបៀបទទួលរាប់ការចូល ចេញ និង ស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា នៃជនបរទេសមិនមែនអន្តោប្រវេសន្ត ដូចមានចែងក្នុងមាត្រា ៧ នៃច្បាប់ស្តីពីអន្តោប្រវេសន៍លើកលែងតែជនបរទេសដែលរស់នៅតាមព្រំប្រទល់ជាប់នឹងខេត្តនានានៃព្រះរាជាណាចក្រកម្ពុជា ដែលជាកម្មវត្ថុ នៃអនុក្រឹត្យ ដោយឡែក ។

**ជំពូកទី ២**

**បែបបទសំរាប់ការចូល ចេញ ព្រះរាជាណាចក្រកម្ពុជា**

**មាត្រា ២._**

ជនបរទេសមិនមែនអន្តោប្រវេសន្តទាំងឡាយណា ដែលមានបំណងចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវដាក់ពាក្យស្នើសុំទិដ្ឋាការចូលព្រះរាជាណាចក្រកម្ពុជា តាមរយៈស្ថានបេសកកម្មទូត ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ឬ តាមរយៈស្ថានតំណាងផលប្រយោជន៍ នៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ។

ចំពោះជនបរទេស ដែលកាន់លិខិតឆ្លងដែនចេញឲ្យ ដោយប្រទេសទាំងឡាយណា ដែលមានចែងក្នុងបញ្ជីកំណត់ដោយក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ

ព្រមទាំង ទេសចរ យានិក នាវិក អ្នកដំណើរឆ្លងកាត់ និង ជនដែលមានសញ្ជាតិដើមជាខ្មែរ រួមទាំងសហព័ទ្ធ និង កូនអាចធ្វើពាក្យសុំទិដ្ឋាការចូលនៅនឹងចំណុចច្រកទ្វារអន្តរជាតិ ដែលកំណត់ដោយរាជរដ្ឋាភិបាល ។

មាត្រា ៣ ._

ការស្នើសុំទិដ្ឋាការត្រូវបំពេញបែបបទដូចតទៅ :

១-បំពេញពាក្យសុំទិដ្ឋាការ ។

២-បង្ហាញលិខិតឆ្លងដែនរបស់ខ្លួន ឬឯកសារណាមួយដែលមានតម្លៃស្មើគ្នា និងដែលមានសុពលភាពយ៉ាងតិច បី ខែ មុនថ្ងៃបញ្ចប់ការស្នាក់នៅព្រះរាជាណាចក្រកម្ពុជា ។

៣-ផ្តល់រូបថត ៤ គុណ ៦ ចំនួន ៣ សន្លឹក ។

៤-បង់អាករតាមការកំណត់ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ។ អាករទិដ្ឋាការនេះមិនត្រូវបានសងវិញទេ ទោះក្នុងករណីនៃការស្នើសុំទិដ្ឋា ការនោះត្រូវបានបដិសេធក៏ដោយ ។

កុមារអាយុក្រោម ១២ ឆ្នាំ ធ្វើដំណើរជាមួយឪពុក ម្តាយ ឬអាណាព្យាបាលមិនចាំបាច់បំពេញបែបបទ ដោយឡែកទេ តែត្រូវចុះឈ្មោះរួមជាមួយឪពុក ម្តាយ ឬអាណាព្យាបាលរបស់ខ្លួន ។

## ជំពូកទី ៣

## ប្រភេទទិដ្ឋាការ រយៈពេល និង អាករទិដ្ឋាការ

មាត្រា ៤ ._

ទិដ្ឋាការអាចជាទិដ្ឋាការប្រើសំរាប់ចូល ចេញ មួយដង ឬច្រើនដង ។

ប្រភេទនៃទិដ្ឋាការរួមមាន :

**១-ទិដ្ឋាការការទូត** កំណត់សំគាល់ដោយអក្សរឡាតាំងធំ A ។ ទិដ្ឋាការនេះសំរាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត និង ក្រុមគ្រួសាររបស់គេ ដែលកាន់លិខិតឆ្លងដែនការទូត ហើយមកបំពេញបេសកកម្មការទូត ឬ ក្នុងលក្ខណៈឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬអាចត្រូវបានផ្តល់ចំពោះជនបរទេសដទៃទៀត ដែលមានការសំរេចពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**២-ទិដ្ឋាការផ្លូវការ** កំណត់សំគាល់ដោយអក្សរឡាតាំងធំ B ។ ទិដ្ឋាការនេះសំរាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលមកបំពេញបេសកកម្មក្នុងក្របខ័ណ្ឌរដ្ឋ ឬក្នុងក្របខ័ណ្ឌអង្គការអន្តរជាតិនានា ដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។ ទិដ្ឋាការនេះក៏សំរាប់ផ្តល់ក្នុងលក្ខណៈឯកជនដែរ ចំពោះជនបរទេសដែលកាន់លិខិតឆ្លងដែនផ្លូវការ ។

**៣-ទិដ្ឋាការមេត្រីភាព** កំណត់សំគាល់ដោយអក្សរឡាតាំងធំ C ។ ទិដ្ឋាការនេះសំរាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ព្រមទាំងក្រុមគ្រួសាររបស់គេដែលក្រសួងការបរ

ទេស និងសហប្រតិបត្តិការអន្តរជាតិ ឬ ក្រសួងនានាចាត់ទុកថាជាការសំដែងនូវការគួរសម ។ ទិដ្ឋាការនេះក៏សំរាប់ផ្តល់ចំពោះគ្រួសារជនបរទេសមិនមែនអន្តោប្រវេសន្តក្នុងចំណុចទី២ មាត្រា៤ នៃអនុក្រឹត្យនេះ ។

**៤-ទិដ្ឋាការទេសចរណ៍** កំណត់សំគាល់ដោយអក្សរឡាតាំងធំ T ។ ទិដ្ឋាការនេះសំរាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តដែលជាទេសចរ ។

**៥-ទិដ្ឋាការធម្មតា** កំណត់សំគាល់ដោយអក្សរឡាតាំងធំ D ។ ទិដ្ឋាការនេះសំរាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលជាអ្នកធ្វើដំណើរឆ្លងកាត់ដែលជាអ្នកបើកបរ ជាបុគ្គលិក កម្មករ នាវា ឬ យន្តហោះ ។

**៦-ទិដ្ឋាការធម្មតា** កំណត់សំគាល់ដោយអក្សរឡាតាំងធំ E ។ ទិដ្ឋាការនេះសំរាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តទាំងឡាយណា ដែលគ្មានរាប់បញ្ចូលក្នុងប្រភេទទិដ្ឋាការណាមួយដូចខាងលើនេះ ។

**៧-ទិដ្ឋាការពិសេស** កំណត់សំគាល់ដោយអក្សរឡាតាំងធំ K ។ ទិដ្ឋាការនេះសំរាប់ផ្តល់ចំពោះជនដែលមានសញ្ជាតិដើមជាខ្មែរ ហើយកាន់កាប់លិខិតឆ្លងដែនបរទេស ។ ទិដ្ឋាការនេះចេញអោយដោយពុំមានបង់អាករទិដ្ឋាការ អាចចេញ ចូល ច្រើនដងបាន ហើយ មានរយៈពេលស្នាក់នៅមិនកំណត់ ។

**មាត្រា ៥ .-**

ទិដ្ឋាការ A B C T D និង E មានសុពលភាព បី ខែ ដោយគិតចាប់តាំងពីថ្ងៃចេញទិដ្ឋាការនោះ។ បើផុតរយះពេល បី ខែ ត្រូវសុំទិដ្ឋាការថ្មី ។ ទិដ្ឋាការពិសេស K មានសុពលភាពមិនកំណត់ ។

ជនបរទេសដែលត្រូវបានអនុញ្ញាតអោយចូលព្រះរាជាណាចក្រកម្ពុជាតាមរយៈទិដ្ឋាការ ដែលផ្តល់ដំបូងអាចស្នាក់នៅ :

-បីខែ ចំពោះទិដ្ឋាការប្រភេទ AB និង C

-មួយខែ ចំពោះទិដ្ឋាការប្រភេទ T និង E

-ប្រាំថ្ងៃ ចំពោះទិដ្ឋាការប្រភេទ D ។

ការបន្តរយះពេលស្នាក់នៅបណ្តោះអាសន្នត្រូវអនុវត្តតាមការកំណត់ដូចមានចែងក្នុងមាត្រា៩ នៃអនុក្រឹត្យនេះ ។

**មាត្រា ៦ .-**

មូលហេតុនៃការស្នាក់នៅជាក់ស្តែង ត្រូវតែស្របតាមប្រភេទនៃទិដ្ឋាការដែលចេញអោយ ។

**មាត្រា ៧ .-**

អាករទិដ្ឋាការត្រូវកំណត់ដូចខាងក្រោម :

-ទិដ្ឋាការ ការទូត A មិនយកអាករ

-ទិដ្ឋាការ ផ្លូវការ B មិនយកអាករ

-ទិដ្ឋាការ ទៅរីភាព C មិនយកអាករ

-ទិដ្ឋាការ ទេសចរណ៍ T អាករស្មើនឹង ម្ភៃ ដុល្លារអាមេរិក

-ទិដ្ឋាការ ឆ្លងកាត់ D អាករស្មើនឹង ដប់ប្រាំដុល្លារអាមេរិក

-ទិដ្ឋាការ ធម្មតា E អាករស្មើនឹង ម្ភៃប្រាំដុល្លារអាមេរិក

-ទិដ្ឋាការពិសេស K មិនយកអាករ ។

## ជំពូកទី ៤

## ការចេញ ការពន្យារ ការបដិសេធន៍ ទិដ្ឋាការ និង ការស្នាក់នៅបណ្តោះអាសន្ន

**មាត្រា ៨ .-**

រយៈពេលបន្តការស្នាក់នៅបណ្តោះអាសន្នត្រូវបានកំណត់ដូចតទៅ :

-ទិដ្ឋាការ ការទូត A អាចបន្តបានពីមួយខែ ដល់ ដប់ពីរខែម្តងរហូតដល់ចប់បេសកកម្ម

-ទិដ្ឋាការ ផ្លូវការ B អាចបន្តបានពីមួយខែដល់ដប់ពីរខែម្តងយ៉ាងយូររហូតដល់ចប់បេសកកម្ម

-ទិដ្ឋាការ ទៅរីភាព C អាចបន្តបានពីមួយខែ ដល់ ដប់ពីខែម្តងយ៉ាងយូរ

-ទិដ្ឋាការ ទេសចរណ៍ T អាចបន្តបានមួយដង និង មិនលើសពី ៣០ ថ្ងៃសំរាប់ការចេញ ចូល តែមួយដង ។

-ទិដ្ឋាការ ឆ្លងកាត់ D មិនអាចបន្តបានទេ លើកលែងតែក្នុងករណីប្រធានសក្តិ

-ទិដ្ឋាការ ធម្មតា E អាចបន្តបាន ពីមួយខែ ដល់ ដប់ពីរខែ ដោយសាមីជនត្រូវមកបង្ហាញខ្លួន ដើម្បីបំពេញបែបបទ ដោយផ្ទាល់នៅស្ថាប័នមានសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។ ចាប់ពីមួយឆ្នាំឡើងទៅសាមីជន ត្រូវសុំប័ណ្ណស្នាក់នៅបណ្តោះអាសន្នពីស្ថាប័នខាងលើ ។

-ទិដ្ឋាការពិសេស K មានរយៈពេលស្នាក់នៅមិនកំណត់ ។

**មាត្រា ៩ .-**

បែបបទស្នើសុំការអនុញ្ញាតបន្តស្នាក់នៅបណ្តោះអាសន្នមានដូចតទៅ :

១-បំពេញពាក្យសុំបន្តស្នាក់នៅបណ្តោះអាសន្ន ។

២-ភ្ជាប់មកជាមួយនូវលិខិតឆ្លងដែន ដែលនៅមានសុពលភាពយ៉ាងតិចបីខែ លើសរយៈពេលស្នើសុំបន្តស្នាក់នៅបណ្តោះអាសន្ន ។

៣-រូបថត ៤ គុណ ៦ ចំនួនមួយសន្លឹក ។

៤-ត្រូវបង់អាករសំរាប់ការអនុញ្ញាតបន្តស្នាក់នៅបណ្តោះអាសន្នតាមការកំណត់ក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ ។

៥-ចំពោះទិដ្ឋាការធម្មតា E ដែលស្នើសុំការអនុញ្ញាតបន្តស្នាក់នៅបណ្តោះអាសន្នចាប់ពីប្រាំមួយខែឡើងទៅ ត្រូវមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នដែលបញ្ជាក់ថាពិតជាមានការចាំបាច់ក្នុងការបន្តស្នាក់នៅបណ្តោះអាសន្នមែន ឬ កិច្ចសន្យាការងារជាមួយរោងចក្រ សហគ្រាស ក្រុមហ៊ុនសិប្បកម្ម ឬ ការដ្ឋានដែលមានការទទួលស្គាល់ពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និង ការងារ ឬ លិខិតបញ្ជាក់ស្តីពីការចុះបញ្ជីពាណិជ្ជកម្មដែលចេញអោយដោយ ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១០ ._

ក- ស្ថានបេសកកម្មការទូត ឬ កុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ឬ ស្ថានតំណាងផលប្រយោជន៍ នៃព្រះរាជាណាចក្រកម្ពុជានៅបរទេសមានសមត្ថកិច្ច ចេញទិដ្ឋាការគ្រប់ប្រភេទ ។

ខ- ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិមានសមត្ថកិច្ច :

-ចេញ និង បដិសេធទិដ្ឋាការប្រភេទ AB និង C

-អនុញ្ញាតបន្តការស្នាក់នៅបណ្តោះអាសន្នសំរាប់ទិដ្ឋាការប្រភេទ AB និង C

-កំណត់ការចេញ ចូលមួយ ឬ ច្រើនដងសំរាប់ទិដ្ឋាការប្រភេទ AB និង C ។

គ-ក្រសួងមហាផ្ទៃមានសមត្ថកិច្ច :

-ចេញទិដ្ឋាការប្រភេទ TDE និង K

បន្តការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នចំពោះទិដ្ឋាការប្រភេទ TD និង E

-បដិសេធទិដ្ឋាការ និង ការអនុញ្ញាតបន្តស្នាក់នៅបណ្តោះអាសន្នចំពោះទិដ្ឋាការប្រភេទ TD និង E

-កំណត់ការចេញ ចូល មួយ ឬច្រើនដងសំរាប់ទិដ្ឋាការប្រភេទ TDE និង K ។

មាត្រា ១១ ._

អាករលើការអនុញ្ញាតបន្តស្នាក់នៅបណ្តោះអាសន្ន ត្រូវកំណត់ដូចខាងក្រោម :

-ស្មើនឹង សាមសិបដុល្លារអាមេរិក សំរាប់ការអនុញ្ញាតបន្តស្នាក់នៅបណ្តោះអាសន្នរយៈពេលក្រោម ឬ ស្មើ មួយខែ

-ស្មើនឹង ហុកសិបដុល្លារអាមេរិក សំរាប់ការអនុញ្ញាតបន្តស្នាក់នៅបណ្តោះ អាសន្នរយៈពេលបីខែ

-ស៊េរីនឹង អ្នករបររបរផុញ្ញូរអាមេរិក សំរាប់ការអនុញ្ញាតបន្តស្នាក់នៅបណ្តោះអាសន្នរយៈពេលប្រាំមួយខែ

-ស៊េរីនឹង អ្នករបររបរប៉ែតសិរះផុញ្ញូរអាមេរិក សំរាប់ការអនុញ្ញាតបន្តស្នាក់នៅបណ្តោះអាសន្នរយៈពេលមួយឆ្នាំ ។

អាការលើការអនុញ្ញាតបន្តការស្នាក់នៅបណ្តោះអាសន្នខាងលើនេះ មិនអនុវត្តចំពោះប្រភេទទិដ្ឋាការ A B C និង K ទេ ។

**មាត្រា ១២ .**

អាការត្រូវប្រមូលខាងលើត្រូវបង់ចូលថវិកាជាតិ ។

តំរិតបែបបទនៃការប្រមូលអាករនេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៥

## ការហាមឃាត់មិនអោយចូល និងមិនអនុញ្ញាត អោយស្នាក់នៅបណ្តោះអាសន្ន

**មាត្រា ១៣ .**

ត្រូវហាមឃាត់មិនអោយចូល និង មិនអោយស្នាក់នៅបណ្តោះអាសន្នក្នុងព្រះរាជាណាចក្រកម្ពុជា ជនបរទេសមិនមែនអន្តោប្រវេសន្តណា ដែលមានមូលហេតុណាមួយដូចខាងក្រោមនេះ :

១-លិខិតឆ្លងដែន ឬ ឯកសារធ្វើដំណើរគ្មានតម្លៃ ។

២-គ្មានកោះត្រាបញ្ជាក់ការចូលប្រទេស ពីមន្ត្រីអន្តោប្រវេសន៍កម្ពុជាប្រចាំនៅច្រកទ្វារអន្តរជាតិ ឬ ស្ថានីយពិណាមួយ ។

៣-វិកលចរិត ។

៤-ពិការភ្នែក មិនអាចចិញ្ចឹមខ្លួនឯង និង ក្រុមគ្រួសារខ្លួន ហើយដែលគ្មានជនណាផ្សេងសង្គ្រោះទំនុកបំរុងឡើយ ។

៥-ពាក់ព័ន្ធនឹងគ្រឿងញៀន ។

៦-ប្រកបរបរពេស្យាចារ ឬ ជំនួញពេស្យាកម្មផ្សេងៗទៀត ។

៧-ធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយគ្មានប័ណ្ណការងារ ។

៨-ធ្លាប់បានបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានការអនុញ្ញាតពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ឬក្រសួងមហាផ្ទៃ ។

៩-គាំទ្រសកម្មភាពបំផ្លិចបំផ្លាញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

១០-បានលួចឡើងជិះនាវា រថយន្ត ឬ យន្តហោះ មកចុះចតនៅព្រះរាជាណាចក្រកម្ពុជា ។

១១-ផ្តល់ជំនួយ ឬ ជួយលាក់បាំងក្នុងការបញ្ជូនជនបរទេសមិនស្របច្បាប់មកក្នុងព្រះរាជាណាចក្រកម្ពុជា ។

១២-គេចវេសពីការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋដែលសាមីខ្លួនបានប្រព្រឹត្ត ។

១៣-ត្រូវក្រសួងមានសមត្ថកិច្ច មានហេតុផលគ្រប់គ្រាន់ជឿថា នឹង ប្រព្រឹត្តសកម្មភាពធ្វើខូចផលប្រយោជន៍សាធារណៈ ឬ សន្តិសុខសាធារណៈ ។

១៤-ក្រសួងមានសមត្ថកិច្ចរកឃើញថាមិនចង់អោយមានវត្តមាននៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ១៤ ._**

រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ឬ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចបដិសេធចោលទិដ្ឋាការ និង ការអនុញ្ញាតអោយស្នាក់នៅ បណ្តោះអាសន្នចំពោះមូលហេតុណាមួយដូចខាងក្រោម :

១-ខ្មាន់ទិដ្ឋាការបានរំលោភលើបទប្បញ្ញត្តិនានានៃច្បាប់ ស្តីពី អន្តោប្រវេសន៍នៃព្រះរាជាណាចក្រកម្ពុជា ។

២-ខ្មាន់ទិដ្ឋាការត្រូវបានកាត់ទោសពីបទឧក្រិដ្ឋ ។

៣-ទិដ្ឋាការដែលបានមកដោយល្បិចក្លែងបន្លំ ឬ ពោលកុហក ។

៤-រដ្ឋមន្ត្រីទាំងពីរយល់ឃើញថាវត្តមានរបស់ខ្មាន់ទិដ្ឋាការ អាចបង្កអោយមានគ្រោះថ្នាក់ដល់សន្តិសុខជាតិ ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

**មាត្រា ១៥ ._**

ជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលស្នាក់នៅហួសរយៈពេលកំណត់ក្រោមសាមសិបថ្ងៃត្រូវបង្ខំអោយបង់ប្រាក់ពិន័យអន្តរការណ៍ប្រាំដុល្លារអាមេរិក ក្នុងមួយថ្ងៃ សំរាប់ថ្ងៃ ដែលលើសហួកនឹង អាគរលើការអនុញ្ញាតបន្តការស្នាក់នៅបណ្តោះអាសន្នរយៈពេលមួយខែ ។

**មាត្រា ១៦ ._**

១-ជនបរទេសមិនមែនអន្តោប្រវេសន្តណា ដែលស្នាក់នៅហួសរយៈពេលកំណត់លើសពី សាមសិបថ្ងៃត្រូវបង្ខំអោយបង់ប្រាក់ពិន័យអន្តរការណ៍ ដោយអនុលោមទៅតាមមាត្រា ១៥ នៃអនុក្រឹត្យនេះហើយត្រូវបញ្ជាអោយចេញផុតពីព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៧ថ្ងៃយ៉ាងយូរ ។

២-ក្នុងករណីរឹងរូស ឬ គេចវេស មិនចេញពីកម្ពុជាតាមការកំណត់ដូចមានចែងក្នុងចំណុចទី១ខាងលើនេះ សាមីជនត្រូវបង្ខំអោយបង់ប្រាក់ពិន័យអន្តរការណ៍ទ្វេគុណ ហើយត្រូវឃាត់ខ្លួនដើម្បីរៀបចំបែបបទបណ្តេញចេញតាមច្បាប់ស្តីពីអន្តោប្រវេសន៍ ។

មាត្រា ១៧ ._

១-ជនបរទេសមិនមែនអន្តោប្រវេសន្តណា ដែលល្មើសនឹងមាត្រា ៦ នៃអនុក្រឹត្យនេះហើយមានសកម្មភាពច្បាស់លាស់បង្ហាញថា បានប្រើប្រាស់ទិដ្ឋាការខុសពីប្រភេទដែលបានស្នើសុំត្រូវពិន័យអន្តរការណ៍ជាប្រាក់ស្មើ នឹងមួយរយដុល្លារអាមេរិកហើយត្រូវបញ្ជូនអោយចេញផុតពី ព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេលប្រាំពីរថ្ងៃយ៉ាងយូរ ។

២-ក្នុងករណីរំលងហួស ឬ គេចវេសមិនចេញពីកម្ពុជា តាមការកំណត់ដូចមានចែងក្នុងចំណុចទី១ ខាងលើនេះសាមីជនត្រូវបង្ខំអោយបង់ប្រាក់ពិន័យអន្តរការណ៍ទ្វេគុណ ហើយត្រូវឃាត់ខ្លួនដើម្បីរៀបចំបែបបទបណ្តេញចេញតាមច្បាប់ស្តីពីអន្តោប្រវេសន៍ ។

មាត្រា ១៨ ._

ប្រាក់ពិន័យអន្តរការណ៍ខាងលើនេះត្រូវបង់ចូលថវិកាជាតិ ។

របៀបនៃការប្រមូលប្រាក់ពិន័យអន្តរការណ៍នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង របស់ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

មាត្រា ១៩ ._

អនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពី របបទទួលរ៉ាប់រងអនុវត្តចំពោះការអនុញ្ញាតអោយជនបរទេសមិនមែនអន្តោប្រវេសន្តចេញ ចូល និង ស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជានិង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២០ ._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ហត្ថលេខា
ស ខេង យូ ហុកគ្រី

រដ្ឋមន្ត្រីក្រសួងការបរទេស
និង សហប្រតិបត្តិការអន្តរជាតិ
ហត្ថលេខា
ហោ ណាំហុង

រដ្ឋមន្ត្រីក្រសួង
សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា
គាត ឈន់

# អនុក្រឹត្យលេខ ៧៦ អនក្រ.បក
## ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រី
## រាជការ និយោជិត កម្មករ ប្រចាំឆ្នាំ ២០០០

****

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការកំណត់រយៈពេលបំពេញការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ លេខ ១៩២/៩៩គបជអ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៩

## សំរេច

**មាត្រា ១**._ អនុញ្ញាតអោយមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជាទាំងអស់បានឈប់សំរាកការងារប្រចាំឆ្នាំ ២០០០ តាមប្រតិទិនខាងក្រោម ៖

| | | |
|---|---|---|
| -ថ្ងៃទី ០១ មករា ឆ្នាំ | ទិវាចូលឆ្នាំសកល | ឈប់ ០១ ថ្ងៃ |
| -ថ្ងៃទី ០៧ មករា ឆ្នាំ | ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ | ឈប់ ០១ ថ្ងៃ |
| -ថ្ងៃទី ០៨ មីនា | ទិវានារីអន្តរជាតិ | ឈប់ ០១ ថ្ងៃ |
| -ថ្ងៃទី១៣-១៤-១៥ មេសា | ទិវាចូលឆ្នាំប្រពៃណីជាតិ | ឈប់ ០៣ ថ្ងៃ |
| -ថ្ងៃទី ០១ ឧសភា | ទិវាពលកម្មអន្តរជាតិ | ឈប់ ០១ ថ្ងៃ |
| -ថ្ងៃទី ១៧ ឧសភា | បុណ្យវិសាខបូជា | ឈប់ ០១ ថ្ងៃ |
| -ថ្ងៃទី ២១ ឧសភា | ព្រះរាជពិធីច្រត់ព្រះនង្គ័ល | ឈប់ ០១ ថ្ងៃ |
| -ថ្ងៃទី ០១ មិថុនា | ទិវាកុមារអន្តរជាតិ | ឈប់ ០១ ថ្ងៃ |
| -ថ្ងៃទី ១៨ មិថុនា | ព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនិនាថ សីហនុ** | ឈប់ ០១ ថ្ងៃ |
| ថ្ងៃទី ២៤ កញ្ញា | ទិវាប្រកាសរដ្ឋធម្មនុញ្ញ និងព្រះរាជពិធីគ្រងរាជសម្បត្តិជាថ្មី របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** | ឈប់ ០១ ថ្ងៃ |
| -ថ្ងៃទី២៧-២៨-២៩ កញ្ញា | បុណ្យភ្ជុំបិណ្ឌ | ឈប់ ០៣ ថ្ងៃ |

-ថ្ងៃទី២៣ តុលា ទិវាសន្ធិសញ្ញាសន្តិភាពក្រុងប៉ារីស ឈប់ ០១ ថ្ងៃ

-ថ្ងៃទី៣០-៣១តុលា និង០១វិច្ឆិកា ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ឈប់ ០៣ ថ្ងៃ

-ថ្ងៃទី០៩ វិច្ឆិកា ទិវាបុណ្យឯករាជ្យជាតិ ឈប់ ០១ ថ្ងៃ

-ថ្ងៃទី១០-១១-១២ វិច្ឆិកា បុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក ឈប់ ០៣ ថ្ងៃ

-ថ្ងៃទី ១០ ធ្នូ ទិវាសិទ្ធិមនុស្ស ឈប់ ០១ ថ្ងៃ

មាត្រា ២ ._ ពេលវេលាឈប់ទាំងឡាយខាងលើ ដែលត្រូវចំថ្ងៃណាមួយនៃថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ( ថ្ងៃសៅរ៍ ឬ ថ្ងៃអាទិត្យ ) ត្រូវបានអោយឈប់ចំនួន ០១ ថ្ងៃ នៃថ្ងៃបន្ទាប់ជាបន្ថែមទៀត ។ ប៉ុន្តែក្នុងករណីត្រូវចំទាំង២ថ្ងៃជាប់គ្នា គឺទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យនោះ ចំនួនថ្ងៃបន្ទាប់ ដែលត្រូវបានអនុញ្ញាតអោយឈប់បន្ថែមជាជំនួស គឺឈប់តែចំនួន ០១ ថ្ងៃប៉ុណ្ណោះ ។

មាត្រា ៣ ._ បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៧៧ អនក្រ.បក**

**ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ**

**របស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីការចាត់តាំង និងការប្រព្រឹត្តិទៅនៃប្រព័ន្ធសវនកម្មផ្ទៃក្នុង
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតអង្គភាពជាតិសំរាប់តំបន់ពាណិជ្ជកម្មសេរី អាស៊ាន
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៩

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ ._**

អនុក្រឹត្យនេះ កំណត់បេសកកម្មរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ និង ការរៀបចំរចនាសម្ព័ន្ធបណ្តាអង្គភាព នៃក្រសួងនេះ ។

## ជំពូកទី ២

## បេសកកម្ម និង រចនាសម្ព័ន្ធ

**មាត្រា ២ ._**

ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មអោយដឹកនាំ និងគ្រប់គ្រងលើវិស័យការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣ ._**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានមុខងារ និងភារកិច្ច ដូចតទៅ ៖

១-ជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការងារការពារ ឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំង សេចក្តីថ្លៃថ្នូរ និងកិត្យានុភាពរបស់ប្រទេសជាតិ

២-រៀបចំការពារ និងអនុវត្តគោលនយោបាយក្រៅប្រទេសរបស់រាជរដ្ឋាភិបាល

៣-ជាទូទៅ តំណាងព្រះរាជាណាចក្រកម្ពុជា ក្នុងការចរចាជាទ្វេភាគី និងពហុភាគី ជាមួយប្រទេសនានា ។

៤-ជាច្រកចេញ ចូលការទូតតែមួយ ក្នុងទំនាក់ទំនងជាមួយប្រទេស និងអង្គការអន្តរជាតិនានា លើរាល់សកម្មភាពរបស់ក្រសួងស្ថាប័ននានាដែលមានទំនាក់ទំនងជាមួយបរទេស ។

៥-ពង្រឹង និងពង្រីកទំនាក់ទំនងនៃព្រះរាជាណាចក្រកម្ពុជាលើគ្រប់វិស័យ រួមមាន ៖ កិច្ចការការទូត កុងស៊ុល និង សហប្រតិបត្តិការអន្តរជាតិ ជាមួយប្រទេស និងស្ថាប័នអន្តរជាតិ នានា

៦-ស្វែងយល់និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល អំពីស្ថានភាព និងការវិវត្តនៃព្រឹត្តិការណ៍អន្តរជាតិសំខាន់ៗ

៧-តំណាង និងការពារផលប្រយោជន៍ជាតិ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរទាំងរូបវន្តបុគ្គល និងនីតិបុគ្គលព្រមទាំងរួមការពារកិត្តិយសជាតិនៅលើឆាកអន្តរជាតិស្របតាមបទប្បញ្ញត្តិ នៃច្បាប់ជាតិ និងអន្តរជាតិ រួមមាន ៖

-គ្រប់គ្រង និងជួយគាំពារមន្ត្រីរាជការ សិស្ស និស្សិត និងប្រជាពលរដ្ឋខ្មែរ ដែលបំពេញបេសកកម្ម កម្មសិក្សា សិក្សានិងធ្វើដំណើរ ឬរស់នៅបរទេសតាមរយៈស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស

-គ្រប់គ្រង និងការពារអង្គភាពរដ្ឋបាល ទ្រព្យសម្បត្តិសាធារណៈ ក្រុមហ៊ុនជាតិ នាវាសមុទ្រ ទូក កប៉ាល់ និង អាកាសយានកម្ពុជា ដែលមានទីតាំង ឬស្ថិតនៅបរទេស ស្របតាមបទប្បញ្ញត្តិ នៃច្បាប់ជាតិ ច្បាប់អន្តរជាតិ និងទំនៀមទំលាប់ប្រពៃណីអន្តរជាតិ

៨. ដឹកនាំ គ្រប់គ្រងស្ថានតំណាង របស់ព្រះរាជាណាចក្រកម្ពុជា ដែលតាំងនៅបរទេស

៩. សហការជាមួយ អាជ្ញាធរមានសមត្ថកិច្ច ក្នុងការមើលការខុសត្រូវ ចំពោះវត្តមាន និងសកម្មភាព ស្ថានតំណាងបរទេស ស្ថានតំណាងអង្គការអន្តរជាតិ និង អង្គការក្រៅរដ្ឋាភិបាលបរទេស ដែលតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយយោងតាមបទប្បញ្ញត្តិនៃច្បាប់ជាតិ ច្បាប់អន្តរជាតិ និងទំនៀមទំលាប់ប្រពៃណីជាតិ និងអន្តរជាតិ

១០. តំរូវសំរួល និង រៀបចំទស្សនកិច្ច គណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជានៅបរទេស និងទទួលគណៈប្រតិភូបរទេស ដែលមកបំពេញបេសកកម្ម ឬ ទស្សនកិច្ចជាផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤ ._**

ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ មានរចនាសម្ព័ន្ធ ដូចតទៅ ៖

**១-អង្គភាពរដ្ឋបាលកណ្តាល មាន ៖**

-អគ្គលេខាធិការដ្ឋាន

-ខុទ្ទកាល័យរដ្ឋមន្ត្រី

-អធិការដ្ឋាន

-អគ្គនាយកដ្ឋានអាស៊ាន ដែលបែងចែកជា ៖

- នាយកដ្ឋាន រដ្ឋបាលទូទៅ សហប្រតិបត្តិការនយោបាយ និងសន្តិសុខ
- នាយកដ្ឋាន សហប្រតិបត្តិការជំនាញ សេដ្ឋកិច្ច និងទំនាក់ទំនងជាដៃគូ

-នាយកដ្ឋាន អាស៊ី ប៉ាស៊ីហ្វិក ក្រៅពីអាស៊ាន

-នាយកដ្ឋាន អាមេរិក
-នាយកដ្ឋាន អឺរ៉ុប
-នាយកដ្ឋាន អាហ្វ្រិក មជ្ឈិមបូព៌ា
-នាយកដ្ឋាន ពត៌មាន និងឯកសារ
-នាយកដ្ឋាន ពិធីការ
-នាយកដ្ឋាន បុគ្គលិក
-នាយកដ្ឋាន ហិរញ្ញវត្ថុ គណនេយ្យ
-នាយកដ្ឋាន រដ្ឋបាល
-នាយកដ្ឋាន ផែនការ
-នាយកដ្ឋាន ច្បាប់ នឹងកុងស៊ុល
-នាយកដ្ឋាន អង្គការអន្តរជាតិ
-នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ
-នាយកដ្ឋាន អង្គការប្រេងកូហ្វូនី ។

**២-ស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស មាន ៖**

-ស្ថានឯកអគ្គរាជទូត និងស្ថានបេសកកម្មអចិន្ត្រៃយ៍ ប្រចាំអង្គការសហប្រជាជាតិ
-ស្ថានតំណាង ប្រចាំអង្គការអន្តរជាតិ ដែលមានលក្ខន្តិកៈការទូត
-ស្ថានអគ្គកុងស៊ុល និងស្ថានកុងស៊ុល
-ស្ថានកុងស៊ុលកិត្តិយស ។

អង្គការលេខរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ។

## ជំពូកទី ៣
## អគ្គលេខាធិការដ្ឋាន

**មាត្រា ៥ .-**

អគ្គលេខាធិការដ្ឋាន មានភារកិច្ច ធ្វើជាសេនាធិការអោយក្រសួងលើការងារ ៖

១-ធានានិរន្តភាព នៃដំណើរការរដ្ឋបាលទូទៅរបស់ក្រសួង

២-សិក្សា ស្រាវជ្រាវ និងលើកគំរោងផែនការ ស្ដីពីការរៀបចំយុទ្ធសាស្ត្រនិងយុទ្ធវិធី ផ្នែកនយោបាយក្រៅប្រទេស និង ការទូត

៣. កិច្ចការអាស៊ាន ។

អគ្គលេខាធិការដ្ឋាន ដឹកនាំដោយ អគ្គលេខាធិការមួយរូប ជាមន្ត្រីរាជការស៊ីវិលជាន់ខ្ពស់បំផុតរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក៏ជា មន្ត្រីជាន់ខ្ពស់កិច្ចការអាស៊ាន ផងដែរ។

អគ្គលេខាធិការ អាចរមដោយអគ្គលេខាធិការរងមួយចំនួន តាមការចាំបាច់ ។

## ជំពូកទី ៤
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា ៦ ._**

ខុទ្ទកាល័យរដ្ឋមន្ត្រីមានភារកិច្ចបំពេញបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានចែងក្នុងមូលបទខាងលើ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូកទី ៥
## អគ្គាធិការដ្ឋាន

**មាត្រា ៧ ._**

អគ្គាធិការដ្ឋាន មានភារកិច្ច ធ្វើជាសេនាធិការអោយក្រសួងលើការងារ ៖

-ត្រួតពិនិត្យរដ្ឋបាល និងហិរញ្ញវត្ថុ របស់អង្គភាព នៃរដ្ឋបាលកណ្តាល និងស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជា នៅបរទេស

-ត្រួតពិនិត្យកិច្ចការអាស៊ាន ។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប អមដោយអគ្គាធិការរងមួយចំនួន តាមការចាំបាច់ ។

## ជំពូកទី ៦
## អគ្គនាយកដ្ឋាន អាស៊ាន

**មាត្រា ៨ ._**

អគ្គនាយកដ្ឋានអាស៊ាន មានភារកិច្ចធ្វើជាសេនាធិការអោយក្រសួងលើការងារ ៖

-សំរបសំរួលរាល់កិច្ចការអាស៊ាន នៅក្នុងទូទាំងប្រទេស និងធ្វើទំនាក់ទំនងអន្តរជាតិ ជាមួយលេខាធិការដ្ឋាន អាស៊ាន និង លេខាធិការដ្ឋានជាតិ នៃប្រទេសអាស៊ាន នានា ព្រមទាំងជាមួយបណ្តាប្រទេសជាដៃគូរបស់អាស៊ានក្នុងឋានៈ ជាលេខាធិការដ្ឋានជាតិអាស៊ាន នៃព្រះរាជាណាចក្រកម្ពុជា

-ធ្វើជាសេនាធិការ និងជាយន្តការការងារប្រចាំថ្ងៃ របស់ប្រព័ន្ធសំរបសំរួលផ្ទៃក្នុង

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

អគ្គនាយកដ្ឋានអាស៊ាន ដឹកនាំដោយ អគ្គនាយកមួយរូប អមដោយ អគ្គនាយករងមួយចំនួន តាមការចាំបាច់ ។ អគ្គនាយកដ្ឋានអាស៊ាន មាននាយកដ្ឋានពីរ ដូចខាងក្រោម ៖

-នាយកដ្ឋាន រដ្ឋបាលទូទៅ សហប្រតិបត្តិការនយោបាយ និងសន្តិសុខ

-នាយកដ្ឋាន សហប្រតិបត្តិការជំនាញ សេដ្ឋកិច្ច និងទំនាក់ទំនងជាដៃគូ

មាត្រា ៩ ._

នាយកដ្ឋាន រដ្ឋបាលទូទៅ សហប្រតិបត្តិការនយោបាយ និងសន្តិសុខ មានភារកិច្ច ៖

**ផ្នែករដ្ឋបាលទូទៅ**

-លើកផែនការប្រចាំឆ្នាំ និង ធ្វើរបាយការណ៍សរុបសកម្មភាពនានា ព្រមទាំង កិច្ចការរដ្ឋបាល បុគ្គលិករបស់អគ្គនាយកដ្ឋាន និងកិច្ចការបណ្តុះបណ្តាលបោះពុម្ព និងផ្សព្វផ្សាយទូទាំងប្រទេសផ្នែក អាស៊ាន ។ តាមដាននិងត្រួតពិនិត្យការងាររបស់គណៈកម្មាធិការថវិកាអាស៊ាន មូលនិធិអាស៊ាន និង គណៈកម្មាធិការ ត្រួតពិនិត្យបញ្ជី គណនេយ្យអាស៊ាន ។

**ផ្នែកសហប្រតិបត្តិការនយោបាយ**

-រៀបចំឯកសារចូលរួមកិច្ចប្រជុំនានា ផ្នែកនយោបាយ មានកិច្ចប្រជុំកំពូល កិច្ចប្រជុំរួមនៃ រដ្ឋមន្ត្រីការបរទេស និងរដ្ឋមន្ត្រីសេដ្ឋកិច្ច កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស កិច្ចប្រជុំពិគ្រោះរួម នៃមន្ត្រីជាន់ខ្ពស់ ផ្នែកនយោបាយនិងមន្ត្រីជាន់ខ្ពស់ ផ្នែកសេដ្ឋកិច្ច កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ផ្នែកនយោបាយ និង កិច្ចប្រជុំនៃ គណៈកម្មាធិការ អចិន្ត្រៃយ៍អាស៊ាន

-តាមដានទំនាក់ទំនង និងវាយតម្លៃ សភាពការណ៍នយោបាយក្នុងតំបន់ ។

**ផ្នែកសហប្រតិបត្តិការសន្តិសុខ**

-សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការរៀបចំឯកសារចូលរួមកិច្ចប្រជុំនានា ផ្នែកសន្តិ សុខមានកិច្ចប្រជុំវេទិកាសន្តិសុខតំបន់ កិច្ចប្រជុំវេទិកាសន្តិសុខតំបន់ ថ្នាក់មន្ត្រីជាន់ខ្ពស់ កិច្ចប្រជុំនៃ ក្រុម ជំនួយការដល់កិច្ចប្រជុំ ស្តីពី វិធានការកសាងទំនុកចិត្ត កិច្ចប្រជុំនៃក្រុមជំនួយការដល់ កិច្ចប្រជុំស្តីពី ការសង្គ្រោះគ្រោះមហន្តរាយ កិច្ចប្រជុំស្តីពីប្រតិបត្តិការថែរក្សាសន្តិភាព កិច្ចប្រជុំក្រុមការងារស្តីពីសន្ធិ សញ្ញា នៃអាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ កិច្ចប្រជុំ ស្តីពីការរុករកយន្តហោះ ឬ នាវាក្នុងភាពអាសន្ន និង ការសង្គ្រោះជនដែលនៅរស់ ក្រោយមានការគ្រោះថ្នាក់យន្តហោះ ឬ នាវា

-តាមដាន ទំនាក់ទំនង និងវាយតំលៃសភាពការណ៍ សន្តិសុខក្នុងតំបន់

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋាន រដ្ឋបាលទូទៅ សហប្រតិបត្តិការនយោបាយ និង សន្តិសុខ ដឹកនាំដោយ ប្រធាន នាយកដ្ឋានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

មាត្រា ១០ ._

នាយកដ្ឋាន សហប្រតិបត្តិការជំនាញ សេដ្ឋកិច្ច និងទំនាក់ទំនងជាដៃគូ មានភារកិច្ច ៖

**ផ្នែកសហប្រតិបត្តិការជំនាញ**

-ជាអ្នកសំរបសំរួលទូទាំងប្រទេស និងជាអ្នកធ្វើទំនាក់ទំនងអន្តរជាតិ ជាមួយលេខាធិការដ្ឋាន អាស៊ាន និងលេខាធិការដ្ឋានជាតិអាស៊ានទាំងអស់ ក្នុងកិច្ចសហប្រតិបត្តិការជំនាញ រួមមាន ៖ វិស័យ

សង្គមកិច្ច ឃោសនា អប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិជ្ជា បរិស្ថាន វប្បធម៌ និងព័ត៌មាន មុខងារសាធារណៈ ច្បាប់ សុខាភិបាល អប់រំ ការងារ និងយុវជន

-តាមដាន និងវាយតំលៃសកម្មភាពក្នុងវិស័យទាំងនោះ ។

**ផ្នែកសហប្រតិបត្តិការសេដ្ឋកិច្ច**

-ជាអ្នកសំរបសំរួលរួមទាំងប្រទេស និងរួមជាមួយក្រសួងពាក់ព័ន្ធធ្វើទំនាក់ទំនងអន្តរជាតិ ជាមួយលេខាធិការដ្ឋានអាស៊ាន និង លេខាធិការដ្ឋានជាតិអាស៊ានទាំងអស់ ក្នុងវិស័យសហប្រតិបត្តិការសេដ្ឋកិច្ចរួមមាន ៖ ពាណិជ្ជកម្ម ឧស្សាហកម្មវិនិយោគ កម្មសិទ្ធិបញ្ញា ស្តង់ដា និងគុណភាព រ៉ែ និងថាមពល ស្បៀងអាហារ កសិកម្ម និងព្រៃឈើ ដឹកជញ្ជូន និងទូរគមនាគមន៍ ទេសចរណ៍ ហិរញ្ញវត្ថុ និងធនាគារ ។

-ជាសមាជិក របស់អង្គភាពជាតិ អាហ្វតា

-តាមដាន និង វាយតំលៃសកម្មភាពក្នុងវិស័យទាំងនោះ ។

**ផ្នែកទំនាក់ទំនងជាដៃគូ**

-ស្រង់សារពត៌មានបច្ចេកទេស និងហិរញ្ញវត្ថុ ពីបណ្តាប្រទេស និងអង្គការជាដៃគូរបស់អាស៊ាន ដើម្បីអភិវឌ្ឍន៍កម្ពុជា

-តាមដាន និង ធ្វើទំនាក់ទំនង ជាមួយគណៈកម្មាធិការអាស៊ាននៅប្រទេសទី៣

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋានសហប្រតិបត្តិការជំនាញ សេដ្ឋកិច្ច និងទំនាក់ទំនងជាដៃគូ ដឹកនាំដោយ ប្រធាននាយកដ្ឋានម្នាក់ និងមានអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ៧

## នាយកដ្ឋាន អាស៊ី ប៉ាស៊ីហ្វិក ក្រៅពីអាស៊ាន

**មាត្រា ១១ ._**

នាយកដ្ឋាន អាស៊ី ប៉ាស៊ីហ្វិក ក្រៅពីអាស៊ាន មានភារកិច្ច ៖

-តាមដាន និងធ្វើការងារនយោបាយ និង ការងារសហប្រតិបត្តិការទ្វេភាគី ជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ី ប៉ាស៊ីហ្វិក ដោយ សហការជិតស្និទ្ធ ជាមួយស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជា នៅបរទេស

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋានអាស៊ី ប៉ាស៊ីហ្វិក ក្រៅពីអាស៊ាន ដឹកនាំដោយ ប្រធាននាយកដ្ឋានមួយរូប និង មានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

## ជំពូកទី ៨

## នាយកដ្ឋាន អាមេរិក

**មាត្រា ១២ .-**

នាយកដ្ឋានអាមេរិក មានភារកិច្ច ៖

-តាមដាន និង ធ្វើការងារនយោបាយ និងការងារសហប្រតិបត្តិការទ្វេភាគី ជាមួយបណ្តាប្រទេសក្នុងតំបន់អាមេរិក ដោយសហការជិតស្និទ្ធ ជាមួយស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជា នៅបរទេស

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋានអាមេរិក ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

## ជំពូកទី ៩

## នាយកដ្ឋាន អឺរ៉ុប

**មាត្រា ១៣ .-**

នាយកដ្ឋាន អឺរ៉ុប មានភារកិច្ច ៖

-តាមដាន និងធ្វើការងារនយោបាយ និង ការងារសហប្រតិបត្តិការទ្វេភាគី ជាមួយបណ្តាប្រទេសក្នុងតំបន់អឺរ៉ុប ដោយសហការជិតស្និទ្ធជាមួយស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជា នៅបរទេស

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋានអឺរ៉ុប ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

## ជំពូកទី ១០

## នាយកដ្ឋាន អាហ្វ្រិក មជ្ឈិមបូព៌ា

**មាត្រា ១៤ .-**

នាយកដ្ឋាន អាហ្វ្រិក មជ្ឈិមបូព៌ា មានភារកិច្ច ៖

-តាមដាន និង ធ្វើការងារនយោបាយ និង ការងារសហប្រតិបត្តិការ ទ្វេភាគី ជាមួយបណ្តាប្រទេស ក្នុងតំបន់អាហ្វ្រិក មជ្ឈិមបូព៌ា ដោយសហការជិតស្និទ្ធ ជាមួយស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា នៅបរទេស

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋានអាហ្វ្រិក មជ្ឈិមបូព៌ា ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

ជំពូកទី ១១

**នាយកដ្ឋាន ពត៌មាន និង ឯកសារ**

មាត្រា ១៥ ._

នាយកដ្ឋានពត៌មាន និងឯកសារ មានភារកិច្ច ៖

-ជាអ្នកនាំពាក្យ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ផ្តល់ពត៌មាន ស្តីពីសភាពការណ៍ និងសកម្មភាព នៃព្រះរាជាណាចក្រកម្ពុជា ជូនស្ថានតំណាងកម្ពុជានៅបរទេស និងស្ថានតំណាងបរទេសនៅកម្ពុជា

-ទាក់ទង វិភាគ និង កែតម្រូវតាមការចាំបាច់ លើមតិសារពត៌មានជាតិ និងអន្តរជាតិ

-គ្រប់គ្រង តំកល់រក្សាឯកសារ និង បណ្ណសារ

-អនុវត្តភារកិច្ចផ្សេងទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋានពត៌មាន និង ឯកសារ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

មាត្រា ១៦ ._

នាយកដ្ឋាន ពិធីការ មានភារកិច្ច ៖

-ជាពិធីការរដ្ឋ នៃរាជរដ្ឋាភិបាល ទន្ទឹមនេះនាយកដ្ឋានពិធីការធ្វើទំនាក់ទំនង ជាមួយព្រះបរមរាជវាំង ព្រឹទ្ធសភា និងរដ្ឋសភា

-ធ្វើការងារពាក់ព័ន្ធ និង ការអនុវត្តន៍ក្បួនច្បាប់ ស្តីពី ពិធីការទូត តាមវិធាន និងទំនៀមទំលាប់ របស់ព្រះរាជាណាចក្រកម្ពុជា និង តាមវិធាន និងទំលាប់អន្តរជាតិ

-ប្រាំមើល លើតសំណើផ្តល់ ពញាប់ ឬ ដកហូតសិទ្ធិ អភ័យឯកសិទ្ធិ និងការលើកលែងពន្ធជូនអង្គទូត អគ្គកុងស៊ុល និង អង្គការអន្តរជាតិ ដែលមានលក្ខន្តិកៈការទូត នៅព្រះរាជាណាចក្រកម្ពុជា

-រៀបចំពិធីទទួល ឥស្សរជនបរទេស ដែលអញ្ជើញមកធ្វើទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា និងទស្សនកិច្ចគណៈប្រតិភូ នៃព្រះរាជាណាចក្រកម្ពុជា នៅបរទេស

-រៀបចំ អាសនានុក្រម ក្នុងពិធីបុណ្យនានា ដែលរៀបចំដោយស្ថាប័នរដ្ឋ

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋានពិធីការ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

## ជំពូកទី ១៣
## នាយកដ្ឋាន បុគ្គលិក

**មាត្រា ១៧ .-**

នាយកដ្ឋាន បុគ្គលិក មានភារកិច្ច ៖

-គ្រប់គ្រងផ្នែករដ្ឋបាល អ្នករាជការក្របខ័ណ្ឌ និង ភ្នាក់ងារសាធារណៈ នៅរដ្ឋបាលកណ្តាល និងនៅស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជា នៅបរទេស ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-រៀបចំរាល់លិខិតរដ្ឋបាល សំរាប់ការគ្រប់គ្រងអាជីព

-ធ្វើកម្មវិធីពីតំណែងឯកទេស និង ធនធានមនុស្សរបស់ក្រសួង

-វាយតំលៃតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក

-រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្តដោយធ្វើទំនាក់ទំនង នឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអនុវត្តនយោបាយនោះ

-រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពត៌មានប្រតិបត្តិ

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋានបុគ្គលិក ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

## ជំពូកទី ១៤
## នាយកដ្ឋាន ហិរញ្ញវត្ថុ គណនេយ្យ

**មាត្រា ១៨ .-**

នាយកដ្ឋាន ហិរញ្ញវត្ថុ គណនេយ្យ មានភារកិច្ច ៖

-លើកគំរោងថវិកាក្រសួង និងតាមដានរំលឹកពីការប្រតិបត្តិ

-ប្រមូលចំណូល នៅក្នុងក្រសួង និង បណ្តាស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជា នៅបរទេសបង់ចូលក្នុងថវិការដ្ឋ អោយបានសមស្របតាមច្បាប់ហិរញ្ញវត្ថុកំណត់

-ប្រមូលផ្តុំ និង សំរបសំរួលជំពូកថវិកា

-តាមដានរំលឹកការគ្រប់គ្រងគណនីពិសេស

-ប្រមូលផ្តុំ និង សំរបសំរួលរាល់ចំណាយរបស់ក្រសួង

-គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តន៍ លទ្ធកម្មសាធារណៈ

-ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំ ជួសជុលសំភារៈ បរិក្ខាររបស់ក្រសួង និងបណ្តាស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជា នៅបរទេស

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងបញ្ជីសារពើភណ្ឌក្នុងក្រសួង និងបណ្តាស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជា នៅបរទេស

-គ្រប់គ្រង ហេរញ្ញវត្ថុ និង ហេរញ្ញប្បទានរបស់រដ្ឋ ការបែងចែកគ្រឿងបន្លាស់ និងប្រេងឥន្ធនៈ

-កាន់បញ្ជីជាប្រចាំ នូវសរុបករបត្រ័ និង គណនេយ្យប្រធាតុ

-ពត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និង បន្ទុកគណនី

-ត្រួតពិនិត្យបច្ចេកទេស នៃការប្រតិបត្តិលទ្ធកម្មសាធារណៈ

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋានហិរញ្ញវត្ថុ គណនេយ្យ ដឹកនាំដោយប្រធាននាយកដ្ឋានម្នាក់ និងមានអនុប្រធានមួយចំនួន ជា ជំនួយការតាមការចាំបាច់ ។

## ជំពូកទី ១៥

## នាយកដ្ឋាន រដ្ឋបាល

**មាត្រា ១៩ ._**

នាយកដ្ឋាន រដ្ឋបាល មានភារកិច្ច ៖

-សំរបសំរួលសកម្មភាពគ្រប់ផ្នែក របស់ក្រសួងនៅរដ្ឋបាលកណ្តាល និង រវាងរដ្ឋបាលកណ្តាល និងស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅបរទេស

-គ្រប់គ្រង និង ចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ក្នុងនោះមាន ៖ ហិបការទូត ទូរលេខសំងាត់ និង បារីសំងាត់

-ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និង គ្រប់គ្រងការងារសម្ដមរបស់ក្រសួង

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋានរដ្ឋបាល ដឹកនាំដោយប្រធាននាយកដ្ឋានម្នាក់ និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

## ជំពូកទី ១៦

## នាយកដ្ឋាន ផែនការ

**មាត្រា ២០ ._**

នាយកដ្ឋាន ផែនការ មានភារកិច្ច ៖

-ប្រមូលផ្តុំស្ថិតិ ពត៌មាន ការងារការបរទេស សហប្រតិបត្តិការ

-វិភាគនិងព្យាករណ៍ស្ថានភាព នៃការវិវត្តន៍នយោបាយក្រៅប្រទេស

-រៀបចំយុទ្ធសាស្ត្រ និង យុទ្ធវិធីផ្នែកនយោបាយក្រៅប្រទេស និង ការទូត

-កសាងផែនការ និង កម្មវិធីរយៈពេលខ្លី មធ្យម វែង លើគ្រប់ផ្នែក

-សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋានផែនការ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

## ជំពូកទី ១៧
## នាយកដ្ឋាន ច្បាប់ និងកុងស៊ុល

មាត្រា ២១ ._

នាយកដ្ឋាន ច្បាប់ និងកុងស៊ុល មានភារកិច្ច ៖

**ក្នុងវិស័យច្បាប់**

-ពិនិត្យ ស្រាវជ្រាវ ឯកសារ និងទឡ្ហីករណ៍សំរាប់ការចរចា ដោះស្រាយបញ្ហាព្រំដែនជាមួយ ប្រទេសជិតខាង

-សហការជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងការការពារអធិបតេយ្យភាព បូរណភាពទឹកដី នៃព្រះ-រាជាណាចក្រកម្ពុជា តាមមធ្យោបាយការទូត និងក្នុងការគ្រប់គ្រងព្រំដែន នៃព្រះរាជាណាចក្រកម្ពុជាស្រប តាមច្បាប់ជាតិ និងអន្តរជាតិ

-តាមដាន សិក្សា ផ្តល់យោបល់លើបញ្ហាច្បាប់ជាតិ និងអន្តរជាតិ ក្នុងទំនាក់ទំនងរវាងព្រះ-រាជាណាចក្រកម្ពុជាជាមួយ រដ្ឋ និង អង្គការអន្តរជាតិ នានា

-ចូលរួមការពិភាក្សា ឬ ចរចា ដែលពាក់ព័ន្ធ នឹងវិស័យនីតិសាស្ត្រ និង តាក់តែងអត្ថបទ ដើម្បីអនុវត្តរាល់នីតិវិធីចាំបាច់ និងអត្ថបទគតិយុត្ត សន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ នានា ។

**ក្នុងវិស័យកុងស៊ុល**

គ្រប់គ្រងកិច្ចការកុងស៊ុល រួមមាន ៖

-ផ្ទៀងផ្ទាត់បញ្ជីអគ្គនាគកុលដ្ឋាន

-ធ្វើនីត្យានុកូលកម្មឯកសារចេញទិដ្ឋាការ និង គ្រប់គ្រងការចេញលិខិតឆ្លងដែនធម្មតា ដល់ ជនកម្ពុជា ដែលរស់នៅបរទេស និង ចេញលិខិតឆ្លងដែនការទូត លិខិតឆ្លងដែនផ្លូវការ និងលិខិតបើក ផ្លូវ

-ការពារផលប្រយោជន៍ជនកម្ពុជានៅបរទេស និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុង ការគ្រប់គ្រងជនបរទេស នៅកម្ពុជា

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋានច្បាប់ និងកុងស៊ុល ដឹកនាំដោយ ប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ១៨

## នាយកដ្ឋាន អង្គការអន្តរជាតិ

**មាត្រា ២២ .-**

នាយកដ្ឋានអង្គការអន្តរជាតិ មានភារកិច្ច ៖

-កិច្ចការអង្គការសហប្រជាជាតិ ស្ថាប័នជំនាញ នៃអង្គការសហប្រជាជាតិ ព្រមទាំងអង្គការអន្តរជាតិ ដទៃទៀត នៅក្នុងពិភពលោក

-ចូលរួមកិច្ចប្រជុំនានា ក្នុងក្របខ័ណ្ឌនោះតាមការចាំបាច់

-សំរបសំរួលកិច្ចការ អង្គការក្រៅរដ្ឋាភិបាល [illegible] នានា ដែលមានទីស្នាក់ការ និង ធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយសហការ [illegible] ក្រសួងពាក់ព័ន្ធ

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋានអង្គការអន្តរជាតិ ដឹកនាំដោយ ប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ១៩

## នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ

**មាត្រា ២៣ .-**

នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ មានភារកិច្ច ៖

-កិច្ចការសហប្រតិបត្តិការអន្តរជាតិ ពហុភាគីក្នុងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ ពាណិជ្ជកម្ម វប្បធម៌ វិទ្យាសាស្ត្របច្ចេកទេស សង្គមកិច្ច និងការអភិវឌ្ឍន៍

-ចូលរួមកិច្ចប្រជុំនានា ក្នុងក្របខ័ណ្ឌនោះតាមការចាំបាច់

-សំរបសំរួលកិច្ចការអង្គការអន្តររដ្ឋាភិបាលនានា ដែលមានកិច្ចសហប្រតិបត្តិការជាមួយព្រះរាជាណាចក្រកម្ពុជា

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ២០

## នាយកដ្ឋាន អង្គការហ្វ្រង់កូហ្វូន

**មាត្រា ២៤ .-**

នាយកដ្ឋាន អង្គការហ្វ្រង់កូហ្វូនី មានភារកិច្ច ៖

-តាមដាន និង ចូលរួមសកម្មភាពគ្រប់វិស័យរបស់អង្គការហ្វ្រង់កូហ្វូនីពីសន្និសីទកំពូលមួយ ទៅសន្និសីទកំពូលមួយទៀត ។

-លើកកំពស់សកម្មភាព សហប្រតិបត្តិការគ្រប់វិស័យ រវាងរាជរដ្ឋាភិបាល និងអង្គការហ្វ្រង់កូហ្វូនី ។

-ជាអ្នកសម្របសម្រួលជាតិ រវាងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ជាមួយអង្គការហ្វ្រង់កូហ្វូនី ក្នុងការធ្វើសហប្រតិបត្តិការ ទ្វេភាគី និងពហុភាគី ពិសេស ក្នុងការផ្សព្វផ្សាយភាសាបារាំង

-ទាក់ទាញជំនួយពីអង្គការហ្វ្រង់កូហ្វូនី ដើម្បីអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ

-អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់អោយ ។

នាយកដ្ឋានអង្គការហ្វ្រង់កូហ្វូនី ដឹកនាំដោយប្រធាននាយកដ្ឋានម្នាក់ និងមានអនុប្រធានមួយចំនួន ជា ជំនួយការតាមការចាំបាច់ ។

## ជំពូកទី ២១

## ស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស

**មាត្រា ២៥ .-**

ស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស មាន ៖

-ស្ថានឯកអគ្គរាជទូត និង ស្ថានបេសកកម្មអចិន្ត្រៃយ៍ ប្រចាំអង្គការសហប្រជាជាតិ

-ស្ថានតំណាង ប្រចាំអង្គការអន្តរជាតិ ដែលមាន លក្ខន្តិកៈការទូត

-ស្ថានអគ្គកុងស៊ុល និងស្ថានកុងស៊ុល

-ស្ថានកុងស៊ុលកិត្តិយស ។

**មាត្រា ២៦ .-**

ស្ថានឯកអគ្គរាជទូត និង ស្ថានតំណាង ឬ ស្ថានបេសកកម្មអចិន្ត្រៃយ៍ នានា ប្រចាំ អង្គការសហប្រជាជាតិ អង្គការអន្តរជាតិនៅបរទេស ដែលមានលក្ខន្តិកៈការទូត ត្រូវដឹកនាំដោយ ឯកអគ្គរាជទូត ជាប្រធានបេសកកម្ម ។

ឯកអគ្គរាជទូតត្រូវតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ច ដោយព្រះរាជក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនិងរបស់រាជរដ្ឋាភិបាល ថ្វាយព្រះមហាក្សត្រ ។

ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព គឺតំណាងអោយរាជរដ្ឋាភិបាលលើគ្រប់វិស័យ ។

**មាត្រា ២៧ .-**

ស្ថានអគ្គកុងស៊ុល ត្រូវដឹកនាំដោយអគ្គកុងស៊ុល ជា ប្រធានបេសកកម្ម ។

ស្ថានកុងស៊ុល ត្រូវដឹកនាំដោយកុងស៊ុល ជា ប្រធានបេសកកម្ម ។

អគ្គកុងស៊ុល ត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

កុងស៊ុល និងកុងស៊ុលកិត្តិយស ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

## ជំពូកទី ២២

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ២៨ .-**

អង្គភាពត្រួតពិនិត្យ ហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ញាត់ណាត់ក្នុងអនុក្រឹត្យលេខ ៥១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

## ជំពូកទី ២៣

## អវសានប្បញ្ញត្តិ

**មាត្រា ២៩ .-**

ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់អង្គភាព នៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ៣០ .-**

ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ស្ថានតំណាងនានា នៃព្រះរាជាណាចក្រកម្ពុជា នៅបរទេស ត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ៣១ .-**

ភារកិច្ចទាំងឡាយណា ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ស្ថាប័នដទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងប្រធានស្ថាប័នដទៃទាំងនោះត្រូវសហការគ្នា ដើម្បីបែងចែកការងារ ទទួលខុសត្រូវ និងអនុវត្តការងារទាំងនោះ តាមរយៈប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ប្រធានស្ថាប័នទាំងនោះ ។

**មាត្រា ៣២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធត្រូវ ទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាម

ភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩
នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

**បានយកសេចក្តីជំរាបជូន :**
**សម្តេចនាយករដ្ឋមន្ត្រី**
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
ហត្ថលេខា
**ហោ ណាំហុង**

★★☆

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩**

**អង្គការលេខរបស់**

**ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**




★★★

# អនុក្រឹត្យលេខ ៧៨ អនក្រ.បក
## ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សំរេច

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១ ._** អនុក្រឹត្យនេះកំណត់ការបង្កើតគណៈកម្មាធិការដឹកនាំការងារថ្នាក់ជាតិ ដើម្បីគ្រប់គ្រងកម្មវិធីអភិវឌ្ឍន៍បែបវិមជ្ឈការរបស់រាជរដ្ឋាភិបាល ហៅថាកម្មវិធីសិលា ដោយមានការចូលរួមអនុវត្តពីគណៈកម្មាធិការអភិវឌ្ឍន៍ជនបទគ្រប់លំដាប់ថ្នាក់ ។

**មាត្រា ២ ._** កម្មវិធីសិលាមានគោលដៅដូចតទៅ ៖

១-រួមចំណែកកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ តាមរយៈការអនុវត្តន៍គោលនយោបាយវិមជ្ឈការ

២-រៀបចំនិងដំណើរការប្រព័ន្ធវិមជ្ឈការ សំរាប់ការរៀបចំផែនការ ហិរញ្ញវត្ថុ និងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ខេត្ត

៣-វាយតំលៃប្រសិទ្ធភាពនៃប្រព័ន្ធវិមជ្ឈការនានា ក្នុងការរួមចំណែកអនុវត្តគោលដៅអភិវឌ្ឍន៍ប្រទេស ។

### ជំពូកទី ២
### សមាសភាព

**មាត្រា ៣ ._** សមាសភាពគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា មានដូចខាងក្រោម ៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៣- រដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |

***

៤- អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៥-អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី និងអតីតយុទ្ធជន សមាជិក

៦- អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ សមាជិក

៧-អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានិងជាអគ្គលេខាធិការនៃគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ អគ្គលេខាធិការ

**មាត្រា ៤ ._** ប្រធានគណៈកម្មាធិការដឹកនាំការងារ នៃកម្មវិធីសិលាមានសិទ្ធិអញ្ជើញប្រធាន ឬ តំណាងស្ថាប័នអាជ្ញាធរដែនដី អោយចូលរួមប្រជុំការងារ តាមការចាំបាច់ ។

## ជំពូកទី ៣

## ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ៥ ._** គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាមានភារកិច្ច ៖

១-សំរបសំរួលការពិភាក្សាគោលនយោបាយបែបវិមជ្ឈការរៀបផែនការ ហិរញ្ញវត្ថុ និងគ្រប់គ្រងកិច្ចការអភិវឌ្ឍន៍នៅមូលដ្ឋាននៃកម្មវិធីសិលា ដែលបាននិងកំពុងអនុវត្តនៅក្នុងខេត្ត ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប រតនគិរី និងខេត្តដទៃទៀត តាមលទ្ធភាពហិរញ្ញវត្ថុរបស់កម្មវិធីសិលា

២-សំរបសំរួលការអនុវត្តន៍កម្មវិធីសិលា រវាងក្រសួងជាសមាជិកគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងខេត្តអនុវត្តកម្មវិធីសិលា

៣-ពិនិត្យ និងអនុម័តផែនការវិនិយោគសិលា ព្រមទាំងវិភាជន៍ធនធាន

៤-តាមដាន ត្រួតពិនិត្យ វាយតំលៃនិងចងក្រងរបាយការណ៍អំពីប្រសិទ្ធភាពនៃការអនុវត្តន៍គោលនយោបាយបែបវិមជ្ឈការក្នុងខេត្តអនុវត្តកម្មវិធីសិលា ជូនរាជរដ្ឋាភិបាល ព្រមទាំងលើកអនុសាសន៍ដើម្បីជាមូលដ្ឋានសំរាប់រាជរដ្ឋាភិបាលរៀបចំគោលនយោបាយវិមជ្ឈការ សំរាប់អនុវត្តទូទាំងប្រទេស

៥-ធ្វើទំនាក់ទំនងនិងសហប្រតិបត្តិការជាមួយភ្នាក់ងារសហប្រជាជាតិសំរាប់អភិវឌ្ឍន៍ និងភ្នាក់ងារសហប្រជាជាតិដទៃទៀត ស្ថាប័នផ្តល់ជំនួយទ្វេនិងពហុភាគី និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងបរទេសដែលផ្តល់ការគាំទ្របច្ចេកទេស និងថវិកាដល់កម្មវិធីសិលា

៦-បណ្តុះបណ្តាលធនធានមនុស្សក្នុងការងារផែនការ ហិរញ្ញវត្ថុ និងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ តាមបែបវិមជ្ឈការ ។

**មាត្រា ៦ ._** គណៈកម្មាធិការដឹកនាំការងារ នៃកម្មវិធីសិលាមានលេខាធិការដ្ឋាន ដែលមានទីស្នាក់ការនៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

លេខាធិការដ្ឋាននេះមានភារកិច្ចដូចខាងក្រោម ៖

១-សំរបសំរួលដំណើរប្រព្រឹត្តទៅរបស់គណៈកម្មាធិការដឹកនាំការងារ នៃកម្មវិធីសិលា មានជាអាទិ៍ ការរៀបចំផែនការការងារប្រចាំឆ្នាំ ការរៀបចំកិច្ចប្រជុំនិងរបៀបវារៈនៃអង្គប្រជុំគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា

២-រក្សានិងផ្សព្វផ្សាយឯកសារទាំងឡាយ ដែលពាក់ព័ន្ធនឹងការអនុវត្តន៍គោលនយោបាយវិមជ្ឈការ

៣-សំរបសំរួលនិងទំនាក់ទំនងការងារជាមួយបណ្តាក្រសួង ដែលជាសមាជិកគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា រវាងគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាជាមួយនឹងស្ថាប័នជាតិដទៃទៀត និងរវាងថ្នាក់ជាតិនិងខេត្តអនុវត្តកម្មវិធីសិលា ។

មាត្រា ៧ ._ លេខាធិការដ្ឋាននេះ ត្រូវបានដឹកនាំដោយអគ្គលេខាធិការនៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា អមដោយអគ្គលេខាធិការរង និងជំនួយការមួយចំនួន តាមការចាំបាច់ ។

មាត្រា ៨ ._ មន្ត្រីបំរើការងារក្នុងលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ជាមន្ត្រីក្របខ័ណ្ឌដែលអាចស្នើសុំពីក្រសួងនិងស្ថាប័ននានា ។

មាត្រា ៩ ._ បង្កើតក្រុមការងារសិលានៅតាមក្រសួង ដែលជាសមាជិកគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ដើម្បីសំរបសំរួលនិងជួយការងារទាំងឡាយរបស់សមាជិកគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ។

ក្រុមការងារសិលានេះ មានភារកិច្ចដូចខាងក្រោម ៖

១-ជាសមភាគីការងាររបស់លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកម្មវិធីសិលា

២-រៀបចំផែនការការងាររបស់ក្រសួងដែលទាក់ទងទៅនឹងការអនុវត្តន៍កម្មវិធីសិលា

៣-ទំនាក់ទំនង និងគាំទ្រមន្ទីរខ្សែបណ្តោយរបស់ខ្លួននៅថ្នាក់ខេត្ត អោយអនុវត្តកម្មវិធីសិលា អោយមានប្រសិទ្ធភាព និងដោះស្រាយរាល់បញ្ហានានា ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន

៤-ពិនិត្យផែនការ និងរបាយការណ៍អនុវត្ត ដែលទទួលបានពីមន្ទីរខ្សែបណ្តោយក្រសួង

៥-សំរបសំរួល និងសហការជាមួយក្រសួងផ្សេងៗ ដើម្បីធានាអោយមានភាពស៊ីសង្វាក់គ្នា ក្នុងការអនុវត្តន៍កម្មវិធីសិលា

៦-ផ្សព្វផ្សាយលទ្ធផល និងបទពិសោធន៍ដែលទទួលបាន ពីការអនុវត្តន៍ប្រព័ន្ធវិមជ្ឈការ តាមរយៈកម្មវិធីសិលានៅក្នុងក្រសួង និងផ្តល់អនុសាសន៍ទាំងឡាយដល់លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា សំរាប់ពិនិត្យនិងពិចារណា ដើម្បីដាក់ជូនគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាអនុម័ត

៧-ពិនិត្យ តាមដានការអនុវត្តន៍កម្មវិធីសិលាតាមវិស័យរបស់ខ្លួននៅថ្នាក់ខេត្ត និងផ្តល់របាយការណ៍ជូនសមាជិកនៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ។

មាត្រា ១០ ._ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ( គអជខ ) ដែលមានអភិបាលខេត្តជាប្រធាន ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងកម្មវិធីសិលានៅថ្នាក់ខេត្ត ។ បន្ថែមលើភារកិច្ចដែលមានចែងក្នុងសេចក្តី

សម្រេចរបស់រាជរដ្ឋាភិបាលលេខ ០២ សសរ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ជនបទ ខេត្ត-ក្រុង គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត មានភារកិច្ចដូចខាងក្រោម ៖

១-ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ខេត្ត

២-ពិនិត្យ និងផ្តល់មតិលើការឯកភាពលើផែនការវិនិយោគសិលា ហើយស្នើមកគណៈកម្មាធិការដឹកនាំការងារកម្មវិធីសិលា ដើម្បីអនុម័ត

៣-អនុម័តការវិភាជន៍មូលនិធិវិនិយោគសិលា អោយស៊ីសង្វាក់នឹងយុទ្ធសាស្ត្រនៃកម្មវិធីសិលា

៤-ជ្រើសរើសតំបន់គោលដៅ ដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ និងលទ្ធភាពធនធានដែលមាន

៥-ជួយជំរុញ និងគាំទ្រកិច្ចសហការប្រកបដោយប្រសិទ្ធភាព រវាងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ផ្នែកឯកជន សង្គមស៊ីវិល និងភ្នាក់ងារអភិវឌ្ឍន៍ជាតិនានា ក្នុងការរៀបចំផែនការនិងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍ជនបទរបស់ខេត្ត

៦-ចាត់ចែងនិងរិះរកវិធានការអនុវត្តគោលនយោបាយវិមជ្ឈការ ដែលបានទទួលពីគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា

៧-ពិនិត្យ និងឯកភាពលើរបាយការណ៍ស្តីពីការអនុវត្តន៍ផែនការវិនិយោគសិលារបស់ខេត្ត ហើយផ្ញើមកគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ។

មាត្រា ១១ ._ ដើម្បីអនុវត្តភារកិច្ចដូចមានចែងក្នុងមាត្រា១០ខាងលើ គអជខ ត្រូវបង្កើតគណៈកម្មាធិការប្រតិបត្តិដែលមានសមាសភាព ភារកិច្ចនិងរចនាសម្ព័ន្ធ តាមការណែនាំរបស់គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាថ្នាក់ជាតិ សំរាប់គ្រប់គ្រងការអនុវត្តន៍ផែនការវិនិយោគសិលាប្រចាំឆ្នាំរបស់ខេត្ត ។

មាត្រា ១២ ._ គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ត្រូវប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សំរាប់ការបើកផ្លូវការរបស់ខ្លួន ។

## ជំពូកទី ៤

## មូលនិធិ

មាត្រា ១៣ ._ ប្រភពនៃមូលនិធិសំរាប់អនុវត្តកម្មវិធីសិលា មានជាអាទិ៍ ៖

១-ជំនួយឥតសំណង និងកម្ចីពីអ្នកផ្តល់ជំនួយទ្វេភាគី និងពហុភាគី

២-ហិរញ្ញប្បទានពីថវិការដ្ឋ ។

មាត្រា ១៤ ._ មូលនិធិដែលកៀរគរបានពីប្រភពដូចមានចែងក្នុងមាត្រា១៣ខាងលើ ត្រូវបានប្រើប្រាស់សំរាប់កិច្ចអភិវឌ្ឍន៍ជនបទតាមបែបវិមជ្ឈការ ហៅថា មូលនិធិអភិវឌ្ឍន៍វិមជ្ឈការ ហើយត្រូវបានគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវរៀបចំបទប្បញ្ញត្តិនិងនីតិវិធីសំរាប់កិច្ចដំណើរការនៃមូលនិធិនេះ ។

មាត្រា ១៥ ._ ក្នុងការគ្រប់គ្រងមូលនិធិនេះ លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកំណែកម្មវិធីសិលា ត្រូវអនុវត្តកិច្ចការដូចតទៅ ៖

១-សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការកៀងគរធនធានក្នុងស្រុកនិងក្រៅប្រទេស សំរាប់កម្មវិធីសិលា

២-សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការតាមដានអនុវត្តកិច្ចព្រមព្រៀងហិរញ្ញវត្ថុ ដែលបានចុះហត្ថលេខា រវាងរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ឬ អ្នកផ្តល់កម្ចី ព្រមទាំងរៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្ញើជូនរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ ឬ អ្នកផ្តល់កម្ចី តាមកាលកំណត់ដែលបានឯកភាពគ្នា

៣-ពិនិត្យតាមដានការផ្ទេរមូលនិធិអភិវឌ្ឍន៍វិមជ្ឈការ អោយទៅគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ដែលអនុវត្តកម្មវិធីសិលា

៤-សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការធ្វើសវនកម្មគណនីរបស់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

មាត្រា ១៦ ._ អនុក្រឹត្យលេខ ៧៩/អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការបង្កើតក្រុមដឹកនាំការងារកម្មវិធីសិលា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១៧ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីនិងរដ្ឋលេខាធិការគ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធដូចមានចែងក្នុងមាត្រា៣ និងអភិបាលខេត្ត ក្រុង ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## អនុក្រឹត្យលេខ ៨៦៤ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ
## អមចំការកៅស៊ូស្នួល

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូស្នួល
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

### សម្រេច

មាត្រា ១ ._ តែងតាំងលោក គី សាវិទ្ធ មន្ត្រីនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមន្ត្រីត្រួតពិនិត្យរដ្ឋ អមចំការកៅស៊ូស្នួល ។

មាត្រា ២ ._ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៨៦៥ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ
## អមចំការកៅស៊ូជុប

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូជុប
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សម្រេច**

មាត្រា ១ ._ តែងតាំងលោក **ហ៊ាង ខុន** អនុប្រធាននាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជា មន្ត្រីត្រួតពិនិត្យរដ្ឋ អមចំការកៅស៊ូជុប ។

មាត្រា ២ ._ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៩៦ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ
## អមចំការកៅស៊ូមេមត់

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូមេមត់
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

មាត្រា ១ ._ តែងតាំងលោក **ង៉ុយ ឌីឌី** មន្ត្រីនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមន្ត្រីត្រួតពិនិត្យរដ្ឋ អមចំការកៅស៊ូមេមត់ ។

មាត្រា ២ ._ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

# អនុក្រឹត្យលេខ ៥៦៧ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ
## អមចំការកៅស៊ូពាមជាំង

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូពាមជាំង
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .**_ តែងតាំងលោក អួន ម៉ុនឆាត់ មន្ត្រីនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមន្ត្រីត្រួតពិនិត្យរដ្ឋ អមចំការកៅស៊ូពាមជាំង ។

**មាត្រា ២ .**_ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៩៦៨ អនក្រ.តត**

**ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ**

**អមចំការកៅស៊ូក្រែក**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូរំព្រាក
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .-** តែងតាំងលោក ម៉ម រិទ្ធី មន្ត្រីនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមន្ត្រីត្រួតពិនិត្យរដ្ឋ អមចំការកៅស៊ូរំព្រាក ។

**មាត្រា ២ .-** ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៨៦៩ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ
## អមចំការកៅស៊ូចំការអណ្តូង

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូចំការអណ្តូង
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ .**_ តែងតាំងលោក **ចណ្ណ សំណាង** មន្ត្រីនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមន្ត្រីត្រួតពិនិត្យរដ្ឋ អមចំការកៅស៊ូចំការអណ្តូង ។

**មាត្រា ២ .**_ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវបំពេញអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៤៧០ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ

## អមចំការកៅស៊ូបឹងកេត

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតចំការកៅស៊ូបឹងកេត
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា ១ ._ តែងតាំងលោក ជាំ សុខុម ប្រធានការិយាល័យនាយកដ្ឋានគ្រប់គ្រងសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជា មន្ត្រីត្រួតពិនិត្យរដ្ឋ អមចំការកៅស៊ូបឹងកេត ។

មាត្រា ២ ._ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវទទួលអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ,ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

បានចុះហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៨៧១ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

សំរេច

មាត្រា ១ ._ ត្រូវបានប្រគេន មេដាយមាសស្ថាបនាជាតិ ថ្វាយសម្តេចព្រះមហាសុមេធាធិបតី ទេព វង្ស ព្រះសង្ឃរាជគណៈមហានិកាយដែលបានបរិច្ចាគព្រះ[illegible] និងបច្ច័យផ្ទាល់ព្រះអង្គចំនួន១២.០០០

ដុល្លារអាមេរិក សំរាប់កសាងផងទង់សាលា និងព្រះវិហារ នៅក្នុងវត្តមុនីប្រសិទ្ធិវង្ស និងវត្តចំប៉ូវីវង្សក្នុងស្រុកពញាឮ ខេត្តកណ្តាល ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៩៧២ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

មាត្រា ១ ._ ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម ឧកញ៉ា **ទេព ឡេង** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាង ផ្លូវលំមួយខ្សែ ប្រវែង ៥.៣០០ ម៉ែត្រ នៅក្នុងឃុំកាកោង ស្រុកមុខកំពូល ខេត្តកណ្តាល ចំណាយអស់ថវិកាចំនួន ៧២.០០០ ដុល្លារអាមេរិក ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

## អនុក្រឹត្យលេខ ៨៧៣ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

### សំរេច

**មាត្រា ១ ._** ត្រូវបានប្រគល់ មេដាយសុវត្ថិ ស្ថាបនាជាតិ ជូនសប្បុរសជន ០៤រូប ដែលបាន បរិច្ចាគអំណោយជាសម្ភារសំណង់ ៩០ តោន សំរាប់ចែកជូនប្រជាពលរដ្ឋ នៅក្នុងស្រុកពញាឮ ខេត្តកណ្តាលដូចមានរាយនាមខាងក្រោមនេះ ៖

| | | |
|---|---|---|
| ១-ឧកញ៉ាសិរី លឹម ឡេង | ទឹកប្រាក់ | ២.៣០០ ដុល្លារអាមេរិក |
| ២-ឧកញ៉ាសិរី សៅ ថ្មីម | ទឹកប្រាក់ | ២.៣០០ ដុល្លារអាមេរិក |
| ៣-ព្រះតេជគុណ ឈុន ឃួន | ទឹកប្រាក់ | ២.៣០០ ដុល្លារអាមេរិក |
| ៤-ព្រះតេជគុណ ង៉ុយ ម៉ិនឈឿន | ទឹកប្រាក់ | ២.៣០០ ដុល្លារអាមេរិក |

**មាត្រា ២ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ៨៧៤ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

**សំរេច**

**មាត្រា ១ ._** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមហ៊ុន TCM Engineering C0. LTD ដែលបានជួយចាក់បេតុង កៅស៊ូក្រាលផ្លូវនៅមុខ និងក្នុងបរិវេណសាលាខេត្តកណ្តាលចំណាយអស់ទឹកប្រាក់ចំនួន ១២.០០០ ដុល្លារអាមេរិក ។

**មាត្រា ២ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៨៧៥ អនក្រ.តត
## ស្តីពីការតែងតាំងអភិបាល ស្រុក-ខណ្ឌ តាមបណ្តាខេត្ត-ក្រុង

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា ១ ._ ត្រូវបានតែងតាំងលោក **ម៉ុក គារ៉េណល** បច្ចុប្បន្នជំនួយការ ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជា អភិបាលស្រុកកំចាយមារ ខេត្តព្រៃវែង ។

មាត្រា ២ ._ បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៤៧៦ អនក្រ.តត

### ស្តីពីការតែងតាំងអភិបាលរង តាមបណ្តា ខេត្ត-ក្រុង

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា ១ ._ ត្រូវបានតែងតាំងលោក **ជាន ហ៊ីម** បច្ចុប្បន្នអភិបាលស្រុកកំចាយមារ ខេត្តព្រៃវែង ជាអភិបាលរងទី២ ខេត្តកោះកុង ។

មាត្រា ២ ._ បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៨៧៧ អនក្រ.តត

## ស្តីពីការផ្លាស់ប្តូរមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ .**_ ត្រូវបានផ្លាស់ប្តូរលោក **អ៊ុខ ទ័ន** បច្ចុប្បន្នអភិបាលរងទី ២ ខេត្តកោះកុង អោយមកបំរើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ដោយរក្សាឋានៈដដែល ។

**មាត្រា ២ .**_ បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង

ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុងដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៨៧៨ អនក្រ.តត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

**មាត្រា ១ .-** តែងតាំងលោក **ង៉ិខ ឆាស៊ាម** ពីក្រឹក្សាអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃឡង់ ឲ្យបំពេញមុខងារបន្ថែម ជាជំនួយការនៃតំណាងអចិន្ត្រៃយ៍កម្ពុជាប្រចាំ ESCAP នៅក្រុងបាងកក ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

## អនុក្រឹត្យលេខ ៨៧៩ អនក្រ.តត
## ស្តីពីការជូនមេដាយមាសការងារ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកម/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### សំរេច

**មាត្រា ១ .**_ ត្រូវបានប្រគល់ **មេដាយមាសការងារ** ជាកិច្ចបច្ឆាមរណៈ ជូនសពឯកឧត្តម ឆា អ៊ិចហ្វ អតីតប្រធានអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងជាប្រធានសំរបសំរួលការិយាល័យត្រួតពិនិត្យប្រព័ន្ធធនាគារវិមជ្ឈការ ដើម្បីជាការរំលឹកដល់ស្នាដៃ និងគុណបំណាច់ ដែលឯកឧត្តមបានចូលរួមយ៉ាងសកម្មក្នុងការកសាង និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។

**មាត្រា ២ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៨៨០ អនក្រ.តត
## ស្តីពីការជូនមេដាយមាសស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកម/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

**មាត្រា ១ .-** ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ប្រគេនព្រះតេជគុណ ខៀវ ឈើយ ព្រះញាណកោសល្យ និងជាប្រធានសមាគមមាតាបិតាសិស្ស ដែលបានជួយកសាងអាគារសិក្សា ០៥ខ្នង មាន២៦បន្ទប់ នៅសាលាបឋមសិក្សាវត្តសំបួរ និងសាលាបឋមសិក្សាជ្រាវ ហើយនិងជួយកសាងសមិទ្ធផលជាច្រើនទៀត នៅក្នុងស្រុកសៀមរាប ខេត្តសៀមរាប ចំណាយថវិកាផ្ទាល់អស់ចំនួន ១៧០.២៩៥ ដុល្លារអាមេរិក ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៤៨១ អនក្រ.តត

## ស្តីពីការជូនមេដាយមាសស្ថាបនាជាតិ

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកម/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

**សំរេច**

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០២ រូប ដែលបានជួយកសាងអាគារសិក្សា ០៤ ខ្នង មាន ១៧ បន្ទប់ និងសម្ភារមួយចំនួនទៀត នៅសាលាបឋមសិក្សាអង្គរក្រៅ និងសាលាបឋមសិក្សាមុខនាគ ស្រុកសៀមរាប ខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម ៖

១-លោក GOTO FUMIO ប្រធានសាសនាព្រឹត្តជប៉ុន បានឧបត្ថម្ភទឹកប្រាក់ចំនួន ៥០.០០០ ដុល្លារអាមេរិក ។

២-លោក MASAYOSHI SOBUE ប្រធានក្រុមហ៊ុនអេឡិចត្រនិច ( LION ) ជប៉ុន បានឧបត្ថម្ភទឹកប្រាក់ចំនួន ៦០.០០០ ដុល្លារអាមេរិក ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាល ខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៨៨២ អនក្រ.តត

## ស្តីពីការបំពាក់មេដាយគ្រឿងឥស្សរិយយសជាតិ

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

- យោងតាមសំណើររបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ .-** ត្រូវបានបំពាក់ឋានន្តរសក្តិថ្នាក់ **ឧសេនីយ៍ឯក** ជូនលោក **គឹម សម្បត្តិ** ជំនួយការឯកឧត្តម**ឯម សំអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអង្គភាពពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៨៨៣ អនក្រ.តត

## ស្តីពីការបំពាក់ឋានន្តរសក្តិនាយនគរបាលជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ .-** ត្រូវបានបំពាក់ឋានន្តរសក្តិថ្នាក់ **ឧសេនីយ៍ឯក** ជូនអស់លោកជំនួយការឯកឧត្តម **សូរ ផន** **អគ្គាធិការ** នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាលក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម ៖។

១-លោក មួង ឃីម

២-លោក និត ចាយ

៣-លោក ឡេង ស៊ុំ

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ៤៨៤ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សំរេច

**មាត្រា ១ .-** តែងតាំងលោក **មុំ គឹមសាន** ជាអគ្គនាយករងបច្ចេកទេស នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងអភិវឌ្ឍន៍ជនបទ ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

## អនុក្រឹត្យលេខ ៤៨៥ អនក្រ.តត
## ស្តីពីការបន្ថែមក្របខ័ណ្ឌក្នុងកងកម្លាំងនគរបាលជាតិ

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតស្រុកត្រពាំងប្រាសាទចំណុះខេត្តឧត្តរមានជ័យ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

មាត្រា ១ ._ ត្រូវបានបន្ថែមក្របខ័ណ្ឌនគរបាលជាតិចំនួន ១៥០ កន្លែង (មួយរយហាសិបកន្លែង) សំរាប់អធិការដ្ឋាននគរបាលស្រុកត្រពាំងប្រាសាទ ដែលទើបបង្កើតថ្មី ។ ក្របខ័ណ្ឌនេះត្រូវបានផ្ទេរពីកងយោធពលខេមរភូមិន្ទដែលស្ថិតក្នុងតំបន់នោះស្រាប់ ។

មាត្រា ២ ._ ប្រាក់បៀវត្ស និងរបបឧបត្ថម្ភផ្សេងៗ របស់កងកម្លាំងនគរបាលនេះ ត្រូវបានផ្តល់ជូនចាប់ពីខែ មិថុនា ឆ្នាំ ១៩៩៩ តទៅ ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងនិងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៥៦ សសរ

## ស្តីពីការបង្កើតគណៈកម្មការចំរុះពិភាក្សាជាមួយគណៈប្រតិភូ អគ្គនាយកដ្ឋានព្រំដែន នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការចំរុះ ពិភាក្សាជាមួយគណៈប្រតិភូអគ្គនាយកដ្ឋានព្រំដែន នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលមានសមាសភាពដូចតទៅ ៖

១-ឯកឧត្តម **ប្រាំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ប្រធាន

២-ឯកឧត្តម **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ ជាអនុប្រធាន

៣-ឯកឧត្តម **ឡុង វិសាលោ** អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៤-ឯកឧត្តម **ឆឹយ ធឿន** អគ្គលេខាធិការរងរាជរដ្ឋាភិបាល សមាជិក

៥-ឯកឧត្តម **ហួន សារ៉ាង** សមាជិកគណៈកម្មការព្រំដែន សមាជិក

៦-លោក **សក់ សេដ្ឋា** អគ្គនាយករងរដ្ឋបាល ក្រសួងមហាផ្ទៃ សមាជិក

៧-ឧត្តមសេនីយ៍ទោ **ឈុំ សុជាតិ** នាយកទីចាត់ការព្រំដែន(ក.ប.ខ.ភ) សមាជិក

៨-ឧត្តមសេនីយ៍ទោ **គីម អាន់** ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន សមាជិក

៩-ឧត្តមសេនីយ៍ត្រី **គីត លីមហៃ** ប្រធាននាយកដ្ឋានបច្ចេកទេសនគរបាលព្រំដែន សមាជិក

១០-ឧត្តមសេនីយ៍ត្រី **ចាន់ អ៊ាន** ប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក សមាជិក

១១-វរសេនីយ៍ឯក **ហ៊ី សាគុណ** អនុប្រធានទី១ នាយកដ្ឋាននគរបាលព្រំដែនទឹក សមាជិក

**ប្រការ ២ :** គណៈកម្មការចំរុះមានភារកិច្ច ៖

-ស្រាវជ្រាវរកឯកសារពាក់ព័ន្ធនឹងបញ្ហាព្រំដែនគោក និងព្រំដែនទឹករវាងកម្ពុជា និងវៀតណាម ។

-ប្រជុំពិភាក្សាត្រៀមខ្លឹមសារពាក់ព័ន្ធ នឹងសហប្រតិបត្តិការតាមព្រំដែន ដើម្បីជួបពិភាក្សាធ្វើការងារជាមួយគណៈប្រតិភូអគ្គនាយកដ្ឋានព្រំដែននៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

**ប្រការ ៣ :** គណៈកម្មការចំរុះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ របស់អនុប្រធានក្នុងករណីប្រធានអវត្តមាន ហើយត្រូវរាយការណ៍លទ្ធផលការងាររបស់ខ្លួនជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ។

**ប្រការ ៤ :** គណៈកម្មការចំរុះនេះ នឹងត្រូវរំសាយក្រោយពេលជួបពិភាក្សាជាមួយគណៈប្រតិភូ អគ្គនាយកដ្ឋានព្រំដែននៃសាធារណរដ្ឋសង្គមនិយមវៀតណាមត្រូវបានបញ្ចប់ ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★☆☆

រាជធានីភ្នំពេញ,ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៥៧ សសរ
## ស្តីពីការបង្កើតក្រុមការងារមួយទទួលបន្ទុកសិក្សាកសាង
## ទីក្រុងពិសេសមួយនៅប្រជុំកោះរុង

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសភាពការណ៍ចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

**ប្រការ ១ :** បង្កើតក្រុមការងារមួយទទួលបន្ទុកសិក្សាកសាងក្រុងពិសេសមួយនៅប្រជុំកោះរុង ដែលមានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| ១-ឯ.ឧ **សុខ អាន** | ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាប្រធាន |
| ២-ឯ.ឧ **អ៊ឹម ឈុនលឹម** | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាអនុប្រធាន |
| ៣-ឯ.ឧ **ហេង ទត្សម៉ុនឆាត** | ឧត្តមទីប្រឹក្សារាជរដ្ឋាភិបាល | ជាអនុប្រធាន |
| ៤-ឯ.ឧ **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៥-ឯ.ឧ **ថោង ខុន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ជាសមាជិក |
| ៦-ឯ.ឧ **ត្រាំ អ៊ីវតឹក** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| ៧-ឯ.ឧ **ថ្លៃ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៨-ឯ.ឧ **ឆាន់ សាផាន** | រដ្ឋលេខាធិការក្រសួងបរិស្ថាន | ជាសមាជិក |
| ៩-ឯ.ឧ **សុខ ចិន្ដា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសមាជិក |
| ១០-តំណាងក្រុងព្រះសីហនុ | | ជាសមាជិក |

**ប្រការ ២ :** ក្រុមការងារនេះ មានបេសកកម្មដូចតទៅ ៖

-សិក្សាស្រាវជ្រាវគ្រប់ទិដ្ឋភាព និងវាយតម្លៃអោយបានត្រឹមត្រូវ ដើម្បីបើកដំណើរការស្ថាបនាទីក្រុងពិសេសមួយនៅ " **ប្រជុំកោះរុង** " ។

**ប្រការ ៣ :** ដើម្បីបំពេញបេសកកម្មខាងលើនេះ ក្រុមការងារខាងលើមានសិទ្ធិ និង ភារកិច្ចដូចតទៅ ៖

-គ្រប់សមាជិកទាំងអស់ត្រូវសកម្មចូលរួមប្រជុំការងារតាមសេចក្តីអញ្ជើញរបស់ប្រធាន ដែលនឹងបែងចែកភារកិច្ចជូនអោយទទួលខុសត្រូវតាមមុខជំនាញរៀងៗខ្លួន ។

-ធ្វើទំនាក់ទំនងជាមួយវិនិយោគិនពាក់ព័ន្ធស្ថាប័នជំនាញដែលពាក់ព័ន្ធ សំដៅប្រមូលនូវទិន្នន័យជាមូលដ្ឋាន ។

-ធ្វើការសិក្សាលំអិតអំពីទិដ្ឋភាពច្បាប់ ទិដ្ឋភាពភូមិសាស្ត្រ ទិដ្ឋភាពសេដ្ឋកិច្ច ទិដ្ឋភាពបរិស្ថាន សាគរសាស្ត្រ ជាអាទិ៍ផ្អែកគមនាគមន៍តាមសមុទ្រ និង លទ្ធភាពអំណោយផលចាំបាច់ទ្រនូវការស្ថាបនាទីក្រុងនេះ ។

-រាយការណ៍អំពីសកម្មភាពជាក់ស្តែងរបស់ក្រុមការងារ ជូនប្រមុខរាជរដ្ឋាភិបាលជ្រាបទាន់ពេលវេលា ។

-រៀបចំផ្នែកជំនាញផ្សេងៗក្នុងករណីចាំបាច់ ដើម្បីសិក្សាប្រមូលទិន្នន័យ ។

-ប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសាធារណការ និង

ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អភិបាលក្រុងព្រះសីហនុ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងឯកឧត្តមដែលមាននាមក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៥៨ សសរ

## ស្តីពីការតែងតាំងទីប្រឹក្សានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតំរូវការការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

ប្រការ ១ : តែងតាំងលោកឧកញ៉ា អូស្តាន ហាសុវ្វាន់ ជាទីប្រឹក្សាសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ : លោកឧកញ៉ា អូស្តាន ហាសុវ្វាន់ ត្រូវអនុវត្តនូវសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៥៩ សសរ

## ស្តីពីការផ្ទេរសិទ្ធិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :** ប្រគល់សិទ្ធិជូន ឯកឧត្តម **អ៊ឹម ឈុនលឹម** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ទទួលបន្ទុកបន្ថែម ជារដ្ឋមន្ត្រីស្ដីទី នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជំនួស ឯកឧត្តម **ហោ ណាំហុង** ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ដោយគិតចាប់ពីថ្ងៃទី២៨ ខែសីហា រហូតដល់ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៩៩ ខាងមុខនេះ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នប្រតិភូរាជរដ្ឋាភិបាល អភិបាល ខេត្ត-ក្រុង និង ឯកឧត្តម **អ៊ឹម ឈុនលឹម** ត្រូវអនុវត្តសេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

## ៣-ផែនការណែនាំ

រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៩

**ផែនការណែនាំលេខ ១១ ផកណ**

**ស្ដីពីការរៀបចំពិធីបុណ្យគ្រងរាជសម្បត្តិជាថ្មីរបស់ព្រះ**
**ករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុព្រះមហាក្សត្រ**
**នៃព្រះរាជាណាចក្រកម្ពុជា និងប្រកាសរដ្ឋធម្មនុញ្ញ**
**និងពិធីបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ**

***

* ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៩ ខាងមុខនេះ គឺជាបុណ្យខួបលើកទី៦ នៃការគ្រងរាជសម្បត្តិជាថ្មី របស់ ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង

ទិវាប្រកាសរដ្ឋធម្មនុញ្ញ ។ គឺថ្ងៃនេះហើយ ដែលប្រជារាស្ត្រខ្មែរក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា បាន សំដែងនូវឆន្ទៈរបស់ខ្លួន ប្រកបដោយមនោសញ្ចេតនាសប្បាយរីករាយរកអ្វីប្រៀបផ្ទឹមពុំបានចំពោះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ ដែលស្តេចព្រះរាជបល្ល័ង្ក ទ្រង់គ្រងរាជ សម្បត្តិជាថ្មីឡើងវិញ ដើម្បីបានគង់នៅជាម្លប់ដ៏សុខត្រជាក់ត្រជុំ គ្រប់ក្រុមរបស់ប្រជារាស្ត្រខ្មែរ ជាកូន ជាចៅ ជាទូលរបស់ព្រះអង្គ ។

*ពីថ្ងៃទី ២៤ ខែ កញ្ញា នេះដែរ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលជាច្បាប់កំពូល ប្រកបដោយខ្លឹមសារពេញលេញបំផុតដែលត្រូវ ដែលសភាធម្មនុញ្ញបានអនុម័ត ក៏ត្រូវបានប្រកាសដ៏ អឱឡារិក ដើម្បីឱ្យប្រើប្រាស់ជាផ្លូវការក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ។

*បុណ្យភ្ជុំបិណ្ឌ និងភ្ជុំបិណ្ឌ ជាបុណ្យប្រពៃណីជាតិដ៏សំខាន់របស់ពុទ្ធសាសនិកខ្មែរគ្រប់រូប ។ ពិធីនេះប្រារព្ធឡើង ដើម្បីឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធនៃបុព្វការីជនទាំងឡាយ មានមាតាបិតា ជីដូន ជីតាជាដើម ដែលបានចាកលោកនេះទៅកាន់លោកខាងមុខផង និងជាឱកាសបានជួបជុំបងប្អូន ញាតិមិត្ត សាច់សាលោហិត ដែលរស់នៅទីផ្សេងៗគ្នា បរលើងពីការងាររវល់ និងការរស់ព្រាត់ក្នុងជីវភាពរស់នៅ ទៅវិញទៅមក ព្រមទាំងបង្កើនបាននូវសាមគ្គីភាពដ៏ល្អរវាងគ្នាផង ។ ឆ្នាំនេះ ពិធីបុណ្យកាន់បិណ្ឌ និង ភ្ជុំបិណ្ឌ ប្រព្រឹត្តទៅពីថ្ងៃ ១ រោច ដល់ថ្ងៃ ១៥ រោច ខែភទ្របទ ត្រូវនឹងថ្ងៃទី ២៥ ខែកញ្ញា ដល់ថ្ងៃទី៩ ខែ តុលា ឆ្នាំ១៩៩៩ តាមប្រពៃណី ។

ដើម្បីសំដែងនូវកតញ្ញូតាធម៌ ចំពោះព្រះអង្គមហាក្សត្រ ថ្វាយព្រះពរសព្ទសាធុការបវរមហា ប្រសើរនិងថ្វាយព្រះរាជកុសលចំពោះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និង សម្តេចព្រះរាជអគ្គមហេសី ជាទីគោរពសក្ការៈស្ងួតទ្រង់គង់នៅក្នុងព្រះបរមរាជសម្បត្តិយូរអង្វែង សំដែងនូវអំណរគុណ គោរព ដោយស្មោះត្រង់ចំពោះរដ្ឋធម្មនុញ្ញ និងដើម្បីបើកឱកាសជូនមនុស្សបរិស័ទបំពេញកុសលតាមសទ្ធាជ្រះថ្លា និងប្រពៃណីជាតិ ពលរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការណែនាំដូចតទៅនេះ ៖

១-គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន គ្រប់ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង ត្រូវតុបតែងលំអរទង់ជា ដោយភ្លើងពណ៌ តាំងព្រះឆាយាល័ក្ខណ៍ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និង សម្តេចព្រះរាជអគ្គមហេសី ដោយមានពាក្យស្លោកថ្វាយព្រះពរ និងសារលិខិតថ្វាយព្រះពរ ព្រមទាំងបំផុសប្រជារាស្ត្រឱ្យដោតទង់ ជាតិគ្រប់គេហដ្ឋាននិងលំនៅអោគារ ។

២-គ្រប់ខេត្ត-ក្រុង ត្រូវចាត់តាំងរៀបចំពិធីបុណ្យទាំងពីខាងលើ ឱ្យបានសមស្របតាមលទ្ធ ភាពជាក់ស្តែងក្នុងក្របខ័ណ្ឌខេត្ត-ក្រុងនីមួយៗ ដោយមានមន្ត្រីសង្ឃថ្នាក់ខេត្ត-ក្រុង មន្ត្រីរាជការថ្នាក់ដឹក នាំខេត្ត-ក្រុង មន្ទីរនានាជុំវិញខេត្ត-ក្រុង ខ័ណ្ឌ-ស្រុក អ្នកមុខអ្នកការ ចូលរួមឱ្យបានឱឡារិក ព្រមទាំង មានកម្មវិធីចុះសួរសុខទុក្ខ តាមមន្ទីរពេទ្យ សណ្ឋាគារកុមារកំព្រាផង ។

៣-ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវធ្វើការណែនាំដល់មន្ទីរវប្បធម៌ខេត្ត-ក្រុង ចាត់តាំងក្រុមតន្ត្រីសិល្បៈ បុរាណ សម័យ សំដែងជូនប្រជារាស្ត្រទស្សនាកំសាន្តសប្បាយ នៅតាមទីធ្លាសាធារណៈ ដើម្បីចូលរួមអបអរសាទរក្នុងទិវាជាប្រវត្តិសាស្ត្រនេះ ។

៤-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ- អន្តរជាតិ ត្រូវមានផែនការបែងចែកតាមក្រសួង រដ្ឋលេខាធិការដ្ឋាន មន្ទីរ ស្ថាប័ន អំពាវនាវសប្បុរសជន អង្គការក្រៅរដ្ឋាភិបាល អង្គការមនុស្សធម៌ ក្រុមហ៊ុនឯកជនជួយឧបត្ថម្ភជាថវិកា សំភារៈ គ្រឿងឧបភោគ បរិភោគផ្សេងៗ ចុះសួរសុខទុក្ខដល់យុទ្ធជនរបួស មានជម្ងឺ កំពុងសំរាកព្យាបាលនៅតាមមន្ទីរពេទ្យ យុទ្ធជនពិការតាមមណ្ឌលពិការ កុមារកំព្រា ចាស់ព្រឹទ្ធាចារ្យគ្មានទីពឹង ដើម្បីសំដែងមនោសញ្ចេតនាអាណិតស្រលាញ់រាប់អាន លើកទឹកចិត្ត និងជួយគ្នាទៅវិញទៅមក ។

៥-ក្រសួងធម្មការ និងសាសនា ត្រូវធ្វើការណែនាំដល់មន្ទីរធម្មការខេត្ត-ក្រុង អោយយកចិត្តទុកដាក់បង្កលក្ខណៈអោយបានល្អប្រសើរប្រគេនព្រះសង្ឃ-ជូនពរបរិស័ទ ក្រោយពិធីកាន់បិណ្ឌ និងភ្ជុំបិណ្ឌតាមប្រពៃណីទំនៀមទម្លាប់ ដោយសទ្ធាជ្រះថ្លា តាមពេលវេលាកំណត់ ។

៦-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវណែនាំដល់អង្គភាពក្រោមឱវាទអោយរៀបចំការការពារសន្តិសុខ រក្សាសណ្តាប់ធ្នាប់សង្គម ក្នុងឱកាសបុណ្យគ្រងរាជសម្បត្តិជាថ្មីរបស់ព្រះមហាក្សត្រ និងទិវាប្រកាសរដ្ឋធម្មនុញ្ញ ព្រមទាំងបង្កលក្ខណៈប្រគេនព្រះសង្ឃ ជូនពរបរិស័ទបំពេញកុសលក្នុងពិធីកាន់បិណ្ឌ ភ្ជុំបិណ្ឌ តាមសំណូមពរនានាដោយសេចក្តីសុខក្សេមក្សាន្ត និងសប្បាយរីករាយ ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសង្ឃឹមថា ថ្នាក់ដឹកនាំគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការ-ដ្ឋាន ស្ថាប័ន និងគ្រប់ខេត្ត-ក្រុង ចាត់តាំងអនុវត្តពិធីបុណ្យនេះ សំរេចបានលទ្ធផលល្អប្រសើរ ស្របតាមប្រពៃណីរបស់ជាតិយើង ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## ពាក្យស្លោកសំរាប់ប្រើប្រាស់ក្នុងពិធីគ្រងរាជសម្បត្តិជាថ្មី នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និង ទិវាប្រកាសរដ្ឋធម្មនុញ្ញ

****

-អបអរសាទរ ខួបលើកទី ៦ នៃការគ្រងរាជសម្បត្តិជាថ្មីរបស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង

-ជាតិ សាសនា ព្រះមហាក្សត្រ

-សូមថ្វាយព្រះពរសម្ដេចឪ និងសម្ដេចម៉ែ សូមអោយព្រះជន្មាយុយឺនយូរ

-ជយោ ! ព្រះរាជាណាចក្រកម្ពុជា

-ជយោ ! សន្តិភាព និងការបង្រួបបង្រួមជាតិ

-ពលរដ្ឋគ្រប់រូប ត្រូវគោរពរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-ការពារដាច់ខាត រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-ជយោ ! សេរីប្រជាធិបតេយ្យ សេរីពហុបក្សនៅកម្ពុជា

***

## IV- ការងារបណ្ដាក្រសួង

### ១-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាល វិជ្ជាជីវៈ និង យុវនីតិសម្បទា

### ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៩

### ប្រកាសលេខ ២៣៩ សកវយ

### ស្ដីពីការបង្កើតគណៈកម្មការ SOS កម្ពុជា

***

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសង្គមកិច្ចការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- យោងអនុស្សរណៈរវាងក្រសួងសង្គមកិច្ចការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងអង្គការ SOS-KDI ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩
- យោងលិខិតឧទ្ទេសនាមលេខ ៥២ សណរ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៩ របស់ក្រសួងសុខាភិបាល
- យោងលិខិតលេខ ១៦៧៨ អយក.ករ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៩៩ របស់ក្រសួងអប់រំ យុវជននិងកីឡា
- ពិនិត្យឃើញការចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការ SOS កម្ពុជាដែលមានសមាសភាពដូចខាងក្រោមនេះ :

១-ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ជាប្រធានកិត្តិយស

២-ឯកឧត្តម **នឹម ថូត** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ជាប្រធានប្រតិបត្តិ

៣-លោក **កែវ សាភាន់** អនុប្រធាននាយកដ្ឋានផែនការស្ថិតិក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ជាអនុប្រធាន

៤-លោក **ម៉ៅ សុវត្ថិ** អនុប្រធាននាយកដ្ឋានសុខុមាលភាពកុមារ ជាសមាជិក

៥-លោកស្រី **ជិន ឈាវ** អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យក្រសួងសុខាភិបាល ជាសមាជិក

៦-លោក **ជន ឈាងលី** អនុប្រធាននាយកដ្ឋានបឋម និងមត្តេយ្យសិក្សា ក្រសួងអប់រំយុវជន និងកីឡា ជាសមាជិក

៧-តំណាងអង្គការ SOS-KDI ចំនួនពីរនាក់ ជាសមាជិក

**ប្រការ ២ :** គណៈកម្មការមានភារកិច្ចទទួលខុសត្រូវដូចខាងក្រោមនេះ :

-តំណាងអោយសមាគម SOS-KDI ដែលសមាគម SOS កម្ពុជាជាសមាជិកមួយ ដោយអនុវត្តនូវគោលបំណង និង ទិសដៅរបស់អង្គការ SOS-KDI នៅព្រះរាជាណាចក្រកម្ពុជា ។

-ធានាថាសមាគមតែងតែប្រតិបត្តិទៅតាមលក្ខន្តិកៈ គោលការណ៍ និង គោលការណ៍ណែនាំអន្តរជាតិរបស់អង្គការ SOS-KDI ព្រមទាំងច្បាប់ និងបទបញ្ញត្តិ ដែលប្រើប្រាស់នៅព្រះរាជាណាចក្រកម្ពុជា ។

-ធ្វើផែនការជារៀងរាល់ឆ្នាំ ដោយឈរលើមូលដ្ឋាននៃបណ្តាអទិភាពអង្គការ SOS-KDI ដែលនាំមកនូវផែនការមួយ ដែលចែងពាក់ទូលំទូលាយ សំរាប់សមាគម ។

-សិក្សាឡើងវិញថវិកាតំរោងកម្មវិធី និងធ្វើអនុសាសន៍ដែលពាក់ព័ន្ធនិងថវិកាទៅជូនអគ្គលេខាធិការដ្ឋានអង្គការ SOS-KDI ដែលមានអំណាច ផ្តល់ការអនុម័តចុងក្រោយទៅលើថវិកា ។

-ត្រួតពិនិត្យមើលទូទៅលើការប្រើប្រាស់ជាទូទៅនូវថវិកា និងទ្រព្យសម្បត្តិរបស់សមាគម ហើយចាត់វិធានការស្របច្បាប់ប្រឆាំងនឹង និយោជិកសមាគម ក្នុងករណីនៅពេលដែលថវិកា និងទ្រព្យសម្បត្តិដែលពោលខាងលើមិនត្រូវបានប្រើប្រាស់អោយចំគោលដៅឬការប្រើប្រាស់នោះរំលោភបំពានច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

-បញ្ជាក់ពីការផ្តល់ការងារ និងការបញ្ចប់ការគ្រប់គ្រងសមាគម និង មាតា SOS ។

-បង្កើត និង បញ្ជាក់ពីលក្ខណ្ឌវិក្ខខ័ណ្ឌនៃសេវាកម្ម ដែលនៅក្នុងលក្ខខ័ណ្ឌទាំងនោះមានបញ្ជាក់ពីវិន័យ និងបទបញ្ញត្តិផ្ទៃក្នុង ទំរង់ការនៃការផ្តល់ការងារ និងបទបញ្ញត្តិការងារដទៃទៀតដោយអនុលោមទៅ

តាមច្បាប់ព្រះរាជាណាចក្រកម្ពុជា និង គោលបញ្ញត្តិរបស់អង្គការ SOS KDI ស្តីពីការគ្រប់គ្រង គ្រប់អង្គភាពរង នាមូលដ្ឋាន និងគំរោងកម្មវិធី ។

-ផ្តល់សិទ្ធិអំណាចដល់សមាជិកផ្នែកគ្រប់គ្រង ឬ និយោជិករបស់សមាគម ក្នុងការចុះហត្ថលេខាលើក្រដាសស្នាម ឬឯកសារផ្សេងៗដែលចាំបាច់ សំរាប់ការអនុវត្តន៍របស់សមាគម ។

-គណៈកម្មការអាចធ្វើការសំរេចចិត្តផ្តល់រង្វាន់ កិត្តិយសដល់អ្នកដែលបានផ្តល់សេវាកម្មលេចធ្លោ ឬ បានចូលរួមចំណែកតាមមធ្យោបាយណាមួយចំពោះសមាគម ។

ប្រការ ៣ : គណៈកម្មការមានទីស្នាក់ការបណ្តោះអាសន្ន អាសយដ្ឋាន ផ្ទះលេខ ០១A ផ្លូវលេខ ៥៧ សង្កាត់ បឹងកេងកង១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

ប្រការ ៤ : គណៈកម្មការមានអ្នកសំរបសំរួល ០១នាក់ដែលតែងតាំងឡើងដោយ កិច្ចសហប្រតិបត្តិការជាមួយក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងអង្គការ SOS-KDI សំរាប់ដំណើរការ ការងាររបស់គណៈកម្មការ ។

ប្រការ ៥ : សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៦ : ឯកឧត្តម លោក លោកស្រី ដែលមានឈ្មោះជាគណៈកម្មការ ប្រតិបត្តិក្នុងប្រការ១ខាងលើមានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

អ៊ិត សំហេង

★★★